# មិត្តសំឡាញ់

**MITH SAMLANH**

# របាយការណ៍ប្រចាំឆ្នាំ២០១០

## មករា_ធ្នូ ឆ្នាំ២០១០


**រៀបចំដោយ: លោក ផេង សៅឆេង**

**ត្រួតពិនិត្យដោយ លោក ម៉ាន ផល្លី និងលោកស្រី ម៉ប់ សុម៉ាយ៉ា**


**ធ្នូ ២០១០**


ផ្ទះលេខ ២១៥ ផ្លូវលេខ ១៣ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ប្រអប់សំបុត្រលេខ ៥៨៨ ភ្នំពេញ,ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៥៩៦ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣)៤២៦ ៧៤៨

អ៊ីមែល: info@mithsamlanh.org គេហទំព័រ: www.mithsamlanh.org

*Mith Samlanh would like to say thanks to our sponsors:*

*- AusAid/HAARP, Credit Lyonnais Securities Asia, Child Support Network, Deutsche Bank, Danchurch Aid, EUROPEAN UNION/German Agro Action/Catholic Committee against Hunger and for Development, Evert en Gisela Boudewijn Stichting, Friends-International, French Embassy, Global Fund, Give2 Asia, Pharmaciens Sans Frontieres , La Chaine de L'Espoir, Mainline, Muslim Aid, Planet Wheeler , Riverview Children Foundation, Save the Children Australia, UNICEF, World Health Organization/ SIDA*

# បញ្ជីនៃអក្សរកាត់

| | |
|---|---|
| CCASVA | សមាគមកុមារកម្ពុជា ប្រឆាំង ទុរភិក្ស និងហិង្សា (ស៊ីកាស្វា) |
| CYTI | បណ្តាញការងាររបស់អង្គការហ្វ្រេន្ទអ៊ិនធើណាសិនណល |
| CCFD | សមាគមកាតូលិកប្រឆាំងនឹងគ្រោះទុរភិក្សដើម្បីអភិវឌ្ឍន៏ |
| DFDL | ក្រុមហ៊ុន DFDL MEKONG (Legal & Tax Advisers) |
| DU | អ្នកប្រើប្រាស់គ្រឿងញៀន |
| HBP | សិប្បកម្មតាមផ្ទះ |
| MDSAVY | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទារាជធានី |
| EU | សហភាពអ៊ឺរ៉ុប |
| FA | ហ្វ្រេន្ទអាល់ឡៃអ៊ិន |
| HIV/ AIDS | មេរោគអេដស៏/ ជម្ងឺអេដស៏ |
| IEC | សំភារៈអប់រំ |
| ICC | អង្គការសហប្រតិបត្តិការអន្តរជាតិដើម្បីកម្ពុជា |
| IDU | អ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ |
| MoEYS | ក្រសួង អប់រំ យុវជន និងកីឡា |
| MoSAVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា |
| MoH | ក្រសួងសុខាភិបាល |
| MMT | ការព្យាបាលឱសថជំនួសមេតាដូន |

| | |
|---|---|
| NGO GPP | គំរោងប្រតិបត្តិល្អរបស់អង្គការក្រៅរដ្ឋាភិបាល |
| NIE | វិទ្យាស្ថានជាតិអប់រំ |
| NSP | កម្មវិធីម្ជុល/សឺរាំង |
| NACD | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន |
| NAA | អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ |
| SoP | បទដ្ឋាននៃនីតិវិធី |
| STDs | ជម្ងឺកាមរោគ |
| TA | ជំនួយការបច្ចេកទេស |
| Tooit-Tooit | ឈ្មោះតូបលក់ផលិតផលសិប្បកម្មតាមផ្ទះនៅក្នុងផ្សារទួលទំពូង លេខ ៤៣៤ |
| UNICEF | អង្គការមូលនិធិកុមារសហប្រជាជាតិ |
| WHO | អង្គការសុខភាពពិភពលោក |

## ហ្វ្រេនឡអាល់ឡៃអ៊ិន_អង្គការមិត្តសំឡាញ់

## គម្រោងកម្មវិធី

### ២០០៧ -២០១១

# លទ្ធផលសកម្មភាពប្រចាំឆ្នាំ ២០១០

| | |
|---|---|
| **ទស្សនៈវិស័យ** | យើងធ្វើការរួមគ្នា ដើម្បីការពារកុមារ/យុវវ័យតាមផ្លូវ និងក្រុមផ្សេងទៀតដែលពាក់ព័ន្ធ តាមរយៈការធ្វើការជាមួយពួកគេ ធ្វើអោយយើងអាចបង្កើតឱកាសថ្មីៗដែលល្អសម្រាប់កសាងអនាគតរបស់ពួកគេ។ |
| **បេសកកម្ម** | អង្គការមិត្តសំឡាញ់គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលបង្កើតឡើងដោយអង្គការហ្វ្រេនឡអ៊ិនធឺណាសិនណល និងជាសមាជិកហ្វ្រេនឡអាល់ឡៃអ៊ិន (Friends Alliance) ដើម្បីធ្វើការជាមួយកុមារ/យុវវ័យតាមផ្លូវ គ្រួសារ និងសហគមន៍របស់ពួកគេ ក្នុងគោលដៅកសាងសមត្ថភាពរបស់ពួកគេដែលធ្វើឡើងតាមរយៈ<br>- **ការផ្តល់ការការពារ** ដល់កុមារ និងយុវវ័យតាមផ្លូវពីការរំលោភបំពានគ្រប់ទម្រង់ដូចមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។<br>- **ការធ្វើសមាហរណកម្ម** កុមារ និងយុវវ័យតាមផ្លូវត្រឡប់ទៅរួមរស់ក្នុងសហគមន៍វិញ ដើម្បីពួកគេអាចចូលរួមយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍន៍សង្គមជាតិរបស់ពួកគេ។<br>- **ការទប់ស្កាត់** កុមារនិងយុវវ័យតាមផ្លូវមិនឱ្យចូលរួមក្នុងសកម្មភាព និង/ឬស្ថានភាពប្រកបដោយគ្រោះថ្នាក់ ដែលនាំឱ្យប៉ះពាល់ដល់អនាគតរបស់ ពួកគេ។<br>- **ការកែលំអ** បែបបទការងាររបស់អង្គការ តាមរយៈការជំរុញឱ្យមានការផ្តួចផ្តើមថ្មីៗដែលល្អ ដោយមានការចូលរួមយ៉ាងសកម្មពីកុមារ និងក្រុមយុវវ័យ។ |

| | | |
|---|---|---|
| | - **ការកែប្រែ**សង្គមគ្រប់ស្រទាប់វណ្ណៈទាំងអស់ ដើម្បីជំរុញឱ្យមានបរិយាកាសអំណោយផល និង ការប្រកាន់យកនូវឥរិយាបថថ្មីដែលល្អត្រឹមត្រូវ ។<br><br>ចាប់តាំងពីឆ្នាំ ១៩៩៤ មក អង្គការមិត្តសំឡាញ់ បានសហការជាមួយនឹងអង្គការហ្វ្រេនឡអ៊ិនធឺណាសិនណល/សមាជិកហ្វ្រេនឡអាល់ឡៃអ៊ិន( Friends Alliance) ដែលបាននិងកំពុងរៀបចំកម្មវិធីថ្មីៗប្រកប ដោយគំនិតច្នៃប្រឌិត និងមានលក្ខណៈពេញលេញក្នុងការកសាងបណ្តាញគាំទ្រដល់គម្រោង ដែលដឹកនាំដោយយុវវ័យ និងបង្កើតនូវសេវាការពារ និងគាំទ្រយ៉ាងរឹងមាំ នៅក្នុងអង្គការ សហគមន៍ និងនៅគ្រប់ស្រទាប់វណ្ណៈទាំងអស់របស់សង្គម ក្នុងគោលដៅធានាឱ្យបាននូវនិរន្តភាពមួយពិតៗ ។ | |
| **គោលបំណងទូទៅ** | បង្កើតសេវាកម្មអនុវត្តន៍ល្អ ជាមួយនឹង/សម្រាប់កុមារ/យុវវ័យតាមផ្លូវ និង ក្រុមពាក់ព័ន្ធនៅក្នុងទីក្រុងភ្នំពេញ និងខេត្តកំពង់ចាម ដោយសហការយ៉ាងជិតស្និទជាមួយនឹងអាជ្ញាធរ- ទីក្រុងភ្នំពេញ និង ខេត្តកំពង់ចាម ។ | |
| **គោលបំណងជាក់លាក់** | **ហេតុផលនៃកិច្ចអន្តរាគមន៍** | **សូចនាករដែលអាចផ្ទៀងផ្ទាត់បានយ៉ាងជាក់ស្តែងលើគោលបំណង** |
| | **I.** ***កម្មវិធីហ្វ្រេនឡអាឡៃអ៊ិន:***បង្កើតគម្រោងហ្វ្រេនឡអ៊ិនធឺណាសិនណលយ៉ាងរឹងមាំ នៅក្នុងអង្គការមិត្តសំឡាញ់ ហើយនឹងក្លាយទៅជាគំរូនៃការអនុវត្តន៍ល្អ ដោយមានការទទួលស្គាល់ជាអន្តរជាតិ ។<br>***II. បណ្តាញការពារសុវត្ថិភាពកុមារ:*** កែលំអការការពារជារួមលើកុមារ និងយុវវ័យតាមផ្លូវនៅក្នុងទីក្រុងភ្នំពេញ និងខេត្តកំពង់ចាមតាមរយៈបណ្តាញការពារ សុវត្ថិភាពកុមារ ។<br><br>**III.** ***អាជីវកម្មសង្គមហ្វ្រេនឡរកប្រាក់ចំណូល:*** បង្កើត | ១. អង្គការមិត្តសំឡាញ់មានទំនាក់ទំនង និងផ្តល់សេវាអនុវត្តន៍ល្អបំផុតដល់កុមារនិងយុវវ័យតាមផ្លូវ ៤៥0.000 នាក់ ។<br><br>២. បណ្តាញការពារសុវត្ថិភាពកុមារ ប្រតិបត្តិការជាមួយនឹងដៃគូ និងសមាជិកដែលមានការទទួលស្គាល់ជាសមាជិកត្រឹមត្រូវចំនួន ៧00រូប នៅឆ្នាំ ២០១១ ។<br><br>៣. ៦0% នៃគម្រោងមាន និរន្តភាពនៅឆ្នាំ ២០១១ ។ |

| | | |
|---|---|---|
| | គំរូអាជីវកម្មសង្គមនិងអាជីវកម្មតាមរយៈការណ្ដុះបណ្ដាល វិជ្ជាជីវៈដែលអាចទ្រទ្រង់ទាំងស្រុងដល់និរន្តភាពផ្នែក ហិរញ្ញវត្ថុ សម្រាប់គម្រោង ។<br><br>IV. ***ការគ្រប់គ្រងរដ្ឋបាល*** **:** ដំណើរការអង្គការដែលមានការអនុវត្តន៏ល្អបំផុតនៅគ្រប់ផ្នែកក្នុងកិច្ចការរដ្ឋបាល ។<br>V. ***និរន្តភាព:*** ឆ្នាំ២០១១ អង្គការមិត្តសំឡាញ់នឹងជាម្ចាស់កម្មសិទ្ធិពេញលេញលើអចលទ្រព្យនៃមជ្ឈមណ្ឌលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំ ។ | ៤. នៅឆ្នាំ២០១១ អង្គការមិត្តសំឡាញ់ ត្រូវបានទទួលស្គាល់ថាជាអង្គការដែលមានប្រព័ន្ធគ្រប់គ្រងរដ្ឋបាលល្អបំផុត ។<br><br>៥. នៅឆ្នាំ២០១១ បំណុលត្រូវបានទូទាត់ក្នុងការទិញអចលនទ្រព្យនៅក្នុងមជ្ឈមណ្ឌលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលអប់រំនៃអង្គការមិត្តសំឡាញ់ ។ |

| | |
|---|---|
| **លទ្ធផលទី១**<br>នៅឆ្នាំ២០១១ អង្គការមិត្តសំឡាញ់ (Mith Samlanh) ត្រូវបានទទួលស្គាល់ថាជាគំរូអនុវត្តន៏ល្អ បំផុតជាអន្តរជាតិ ដែលផ្តល់នូវសេវាកម្មគ្រប់ ផ្នែកដល់កុមារ និង យុវវ័យតាមផ្លូវ(ទំនាក់ទំនង)ចំនួន ៤៥០.០០០ នាក់ក្នុងមួយឆ្នាំ ក្រោមការសហការជាមួយនឹងអាជ្ញាធរជាតិ ដែលពាក់ព័ន្ធ ។ | • បទដ្ឋាននៃនិតិវិធី (SoPs) នៃគម្រោងក្នុងអង្គការមិត្តសំឡាញ់មួយចំនួនកំពុងអនុវត្ត និងមួយចំនួនទៀតកំពុងកែសំរួលក្រោមការគាំទ្រពីជំនួយការបច្ចេកទេស នៃអង្គការហ្វ្រេន្ឌអ៊ិនធឺណាសិនណល ។<br>• ក្នុងឆ្នាំ ២០១០ អង្គការមិត្តសំឡាញ់បានផ្តល់សេវាកម្មគ្រប់ផ្នែកដល់កុមារ និង យុវវ័យតាមផ្លូវពីក្រុមការងារដែលទទួលលទ្ធផលដូចតទៅ:<br>- **ចំនួនសេវាសរុប: ១,៤៦០,៨៤០ ( ស្រី ៣៧១,៧៦២នាក់)**<br>- **ចំនួនកុមារ/យុវវ័យសរុប: ១២,៧០០ នាក់ (ស្រី ៤,៩៣១ នាក់)**<br>• ដោយមានការសហការដ៏ល្អ ជាមួយអង្គការដៃគូ និង អាជ្ញាធរជាតិពាក់ព័ន្ធ តាមការអនុវត្តសេវាកម្មគ្រប់ផ្នែករបស់ខ្លួនអង្គការមិត្តសំឡាញ់បាននឹងកំពុងអនុវត្តជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ ស្នងការនគបាលរាជធានីភ្នំពេញ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិង យុវនីតិសម្បទា ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿង |

| | |
|---|---|
| | ញៀន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមការងារគ្រឿងញៀនពាក់ពន្ធ័មេរោគអេដស៍/ជម្ងឺអេដស៍ មន្ទីរសង្គមកិច្ច ខេត្តកំពង់ចាម មន្ទីរអប់រំ យុវជន និង កីឡា សាលារៀនរដ្ឋ មជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញ និងមជ្ឈមណ្ឌលវប្បធម៌បារាំង ព្រះបរមរាជវាំង សារមន្ទីរជាតិ និងសារមន្ទីរទួលស្លែង តាមរយៈការប្រជុំការពិគ្រោះយោបល់ ការបណ្តុះបណ្តាលការងារសមាហរណកម្ម ទស្សនកិច្ចសិក្សា និងការផ្លាស់ប្តូរបទពិសោធន៏ លើការងារអនុវត្តជាមួយគ្នាក្នុងមូលដ្ឋានលើការងារកុមារ/យុវវ័យតាមផ្លូវ។ |
| **លទ្ធផលទី២**<br>នៅឆ្នាំ ២០១១ ដៃគូបណ្តាញការពារ សុវត្ថិ ភាពកុមារ (Child Safe Network) ចំនួន ៧00 នឹងការពារ គាំទ្រដល់កុមារចំនួន ៥.000នាក់ នៅក្នុងទីក្រុងភ្នំពេញ និងខេត្តកំពង់ចាម។ | បណ្តាញការពារសុវត្ថិភាពកុមារ និងសមាជិកនៅក្នុងទីក្រុងភ្នំពេញ និងកំពង់ចាម សរុបចំនួនៈ៦៦៣ នាក់ (ថ្មី១២៩នាក់ )<br>▪ **បណ្តាញដៃគូរសុវត្ថិភាពកុមារ**<br>- ១៥៦ នាក់ (ថ្មី ៣៣) ជាបុគ្គលិកធានាគារ ANZ Royal Bank<br>▪ **សមាជិកសុវត្ថិភាពកុមារ**<br>- ភ្នំពេញ ៣៨៤ នាក់ (ថ្មី ៧១នាក់)<br>- កំពង់ចាម ១២៣នាក់ (ថ្មី ២៥នាក់)<br>កុមារចំនួន ១៣,៤៤០នាក់ (ស្រី៤,៦៤០នាក់) រួមបញ្ចូលកុមារថ្មីចំនួន ៣,២៣៥០នាក់(ស្រី១,១៧១នាក់) ទទួលបានការគាំទ្រ និងការពារដោយបណ្តាញសុវត្ថិភាពកុមារក្នុងឆ្នាំ២០១០ នៅភ្នំពេញ និងខេត្តកំពង់ចាម។ |
| **លទ្ធផលទី៣**<br>នៅឆ្នាំ ២០១១ គម្រោងមាននិរន្តភាព ៦0% តាមរយៈការបង្កើតកម្មវិធីអាជីវកម្ម តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈនិងអាជីវកម្មសង្គម។ | ក្នុងឆ្នាំ២០១០ អង្គការមិត្តសំឡាញ់ទទួលបាននិរន្តភាពហិរញ្ញវត្ថុចំនួន ៤៤% ដែលបានបង្កើតឡើងដោយកម្មវិធីអាជីវកម្មតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជីវកម្មសង្គម ។ អាជីវកម្មបាននឹងកំពុងដំណើរការនៅក្នុងទីក្រុងភ្នំពេញ រួមមានៈ<br>- ភោជនីដ្ឋានហ្រ្វេនឡ<br>- ភោជនីដ្ឋានរំដេង<br>- កាហ្វេមិត្តសំឡាញ់<br>- ហាងលក់ទំនិញហ្រ្វេនឡ អេន ស្តាហ្វ |

| | |
|---|---|
| | - មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- សៀវភៅធ្វើមុខម្ហូប<br>- អាជីវកម្មសហគមន៍<br>*ចំណាំ: និរន្តភាពហិរញ្ញវត្ថុ គឺជាប្រាក់ចំណូលដែលបានមកពីការលក់ផលិតផលនៃគំរោងអាជីវកម្ម/ការចំណាយសរុបនៃគម្រោង។ |
| **លទ្ធផលទី៤**<br>នៅឆ្នាំ២០១១ អង្គការមិត្តសំឡាញ់ (MithSamlanh) ត្រូវបានទទួលស្គាល់ថាជាអង្គការមានប្រព័ន្ធរដ្ឋបាលល្អបំផុត។ | • អង្គការមិត្តសំឡាញ់ត្រូវបានទទួលស្គាល់ ដោយគម្រោងប្រតិបត្តិល្អរបស់អង្គការមិនមែនរដ្ឋាភិបាលតាំងពីឆ្នាំ២០០៧ ដោយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (ស៊ីស៊ីស៊ី) កំពុងបន្តការចែករំលែកបទពិសោធន៍ដល់អង្គការដទៃផ្សេងទៀត និងបានរៀបចំឯកសារដើម្បីបន្តសុពលភាព។<br>• បទបញ្ជាផ្ទៃក្នុងរបស់អង្គការមិត្តសំឡាញ់បានបញ្ចប់ និងបានការឯកភាពពីសមាជិកក្រុមប្រឹក្សាភិបាល បន្ទាប់មកបានធ្វើបទបង្ហាញជូនដល់ប្រធានក្រុម អ្នកគ្រប់គ្រប់គំរោង និងគណៈគ្រប់គ្រង់ទាំងអស់នៅក្នុងឆ្នាំនេះ។ |
| **លទ្ធផលទី៥**<br>នៅឆ្នាំ២០១១ អង្គការមិត្តសំឡាញ់ (Mith Samlanh) ទទួលបានកម្មសិទ្ធិទាំងស្រុងលើអចលនទ្រព្យ និងបានសាងសង់មជ្ឈមណ្ឌល ដែលផ្តល់នូវបរិយាកាសប្រកបដោយគុណភាពសម្រាប់ការងាររបស់ខ្លួន។ | • យុទ្ធការទិញដីនៃអង្គការមិត្តសំឡាញ់បានបញ្ចប់ដោយជោគជ័យ ព្រមទាំងបានទូរទាត់សងធនាគារ ANZ Royal រួចរាល់អស់ហើយ។ ទោះបីជាយ៉ាងណាមិត្តសំឡាញ់នៅជំពាក់អង្គការ Give2Asia ចំនួន២៤៦,១៦២.៦៩ ដុល្លា ជាមួយការប្រាក់ ២ ភាគរយ។<br>• អង្គការមិត្តសំឡាញ់បានទំនាក់ទំនងជាមួយ DFDLក្នុងការរៀបចំឯកសារអចលៈទ្រព្យរបស់យើង ដើម្បីយកសិទ្ធិកាន់កាប់ស្របច្បាប់ជាក្រុមហ៊ុនមិត្តសំឡាញ់។ |

| សកម្មភាព | លទ្ធផលរំពឹងទុក | លទ្ធផលសំរេចបាន |
|---|---|---|
| **លទ្ធផលទី១: នៅឆ្នាំ ២០១១ អង្គការមិត្តសំឡាញ់ (Mith Samlanh) ត្រូវបានទទួលស្គាល់ថាជាគំរូអនុវត្តន៍ល្អបំផុតជាស្តង់ដារអន្តរជាតិ ដែលផ្តល់នូវសេវាកម្មគ្រប់ផ្នែកដល់កុមារ និងយុវវ័យតាមផ្លូវដែលនឹងត្រូវធ្វើ( ទំនាក់ទំនង) ចំនួន ៤៥០.០០០ នាក់ក្នុងមួយឆ្នាំក្រោមកិច្ចសហការជាមួយនឹងអាជ្ញាធរជាតិដែលពាក់ព័ន្ធ។** | | |
| ១.១បទដ្ឋាននីតិវិធី(SoPs) នៃ កម្មវិធីប្រែឡអ៊ិនធឺណាសិន ណលត្រូវបានអនុវត្តក្នុងគម្រោងរបស់អង្គការមិត្តសំឡាញ់ (Mith Samlanh) ទាំងអស់។ | -បទដ្ឋាននីតិវិធី (SoPs)នៃសេវាកម្មមូលដ្ឋានទាំងអស់ត្រូវបានអនុវត្ត នៅឆ្នាំ ២០០៩។<br><br>- បទដ្ឋាននីតិវិធី (SoPs)នៃសេវាកម្មមូលដ្ឋានទាំងអស់ ត្រូវបានធ្វើឱ្យប្រសើរឡើងជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ ២០១០។ | • បទដ្ឋាននៃនិតិវិធី **(SoPs)** សំរាប់គម្រោងមួយចំនួន ក្នុងអង្គការមិត្តសំឡាញ់កំពុងអនុវត្តរួមមានៈ<br>- បទដ្ឋាននៃនិតិវិធីការពារកុមារ<br>- បទដ្ឋាននៃនិតិវិធីរបស់គម្រោងតាមផ្លូវ<br>- បទដ្ឋាននៃនិតិវិធីសំរាប់ឱសថបន្សាប និងការប្រើប្រាស់ ហើយនិងមាត្រដ្ឋានកាត់បន្ថយការឈឺចាប់។<br>• បទដ្ឋាននៃនិតិវិធី (SoPs) និងសៀវភៅណែនាំសំរាប់គម្រោងមួយចំនួនទៀត ក្នុងអង្គការមិត្តសំឡាញ់កំពុងពង្រាង និងកែសម្រួលរួមមានៈ<br>- សៀវភៅណែនាំសំរាប់មណ្ឌលសំចត ការគ្រប់គ្រង់ករណី និងការធ្វើសមាហរណកម្មទៅសាលា និង គ្រួសារ។<br>- សៀវភៅណែនាំសំរាប់បំណិនជីវិត និងការធ្វើសមាហរណកម្ម<br>- បទដ្ឋាននៃនិតិវិធីសំរាប់មេរោគអេដស៍/ជម្ងឺអេដស៍<br>- បទដ្ឋាននៃនិតិវិធី សំរាប់សិប្បកម្មតាមផ្ទះ |
| ១.២.ផ្តល់សេវាអនុវត្តន៍ល្អបំផុតដល់កុមារ និង យុវវ័យតាមផ្លូវចំនួន ៤៥០.០០០ | -កម្មវិធីនេះផ្តល់នូវសេវាសមាហរណកម្មសង្គមជាស្ទូលរួមមាន (គំរោងបង្ការទប់ស្កាត់/សមាហរណកម្ម/តាមផ្លូវ/ | • **សរុបចំនួនសេវាៈ ១,៤៦០,៨៤០ ដង (ស្រី៣៧១,៧៦២ដង)**<br>- គំរោងតាមផ្លូវៈ ៦១០,៧៤៤ ដង (ស្រី១៦៤,៦០៣ដង)<br>- មណ្ឌលស្នាក់នៅបណ្តោះអាសន្នៈ ៦៣០,០០០ដង(ស្រី១៣១,០៤០ដង) |

| | | |
|---|---|---|
| នាក់ /មួយឆ្នាំ។ | ផ្ទះស្នាក់នៅបណ្ដោះអាសន្ន/ការអប់រំ/គ្រឿងញៀន/សមាហរកម្ម ដល់កុមារ និងយុវវ័យតាមផ្លូវចំនួន:៤៥០.០០០នាក់ ដែលគិតជាចំនួនសេវាទំនាក់ទំនងក្នុងមួយឆ្នាំ។<br>- ចំនួនកុមារ/យុវវ័យ ៧.៥០០ នាក់ទទួល បានសេវាកម្មនៅឆ្នាំ២០១១។<br><br>- សេវាកម្មជាក់លាក់ទៅតាម តម្រូវការត្រូវបានកំណត់ និងបង្កើតឡើង និងផ្ដល់ជូន។ | - គំរោងអប់រំ: ២០៦,០៩៧ ដង ( ស្រី៧០,៦១៥ ដង)<br>- សមាហរកម្ម: ១៣,៩៩៩ ដង ( ស្រី៥,៥០៤ដង)<br><br>• **សរុបចំនួនកុមារ/យុវវ័យ: ១២,៧០០នាក់ ( ស្រី៤,៩៣១នាក់)**<br>- គំរោងតាមផ្លូវ: ៨,២២១នាក់ ( ស្រី៣,៣០២ នាក់)<br>- គំរោងអប់រំ: ២,៧៥៦នាក់ ( ស្រី៩២២ នាក់)<br>- គំរោងសមាហរកម្ម: ១,៧២៣ នាក់ ( ស្រី៧០៧ នាក់)<br><br>❶ **<u>តាមផ្លូវ</u>**<br>- ចំនួនសេវាសរុប ៤៨២,៦២៥ ដង( ស្រីចំនួន១៣៩,០៤៦ដង) ក្នុងនោះមានកុមារ/យុវវ័យសរុបចំនួន៨,០១៤នាក់ ( ស្រី៣,២៨៣នាក់)រួមបញ្ចូលថ្មី ១,៥៧០នាក់ ( ស្រី៧៥៨នាក់)និងឪពុក/ម្ដាយចំនួន ១,៥៤៩ ដែលកំពុងរស់នៅ និងធ្វើការតាមផ្លូវ និងសហគមន៍ ទទួលបានសេវា កម្មផ្សេងៗតាមរយៈ តំបន់គោលដៅសំខាន់ៗ ចំនួន ៥ និងមណ្ឌលសំចតនីមួយៗរួមមាន: តំបន់មាត់ទន្លេ (ក្លឹបប្រេីនឡ) តំបន់វត្តភ្នំ( មណ្ឌលស្នាក់នៅពេលថ្ងៃ) តំបន់អូឡាំពិក( ផ្ទះមិត្តភាព) មណ្ឌលព័ត៌មានយុវវ័យ(ខ្ញុំនិងអ្នក) និងមណ្ឌលថែរក្សាពេលថ្ងៃ) ច្បារអំពៅ ( មណ្ឌលយុវវ័យឆ្លាត) សហគមន៍អណ្ដូង( មណ្ឌលអណ្ដូង) លើសពីនេះទៀតយើងមានមណ្ឌលសំចតចល័តចំនួន ២ ដើម្បីគាំទ្រតំបន់នីមួយៗដល់ក្រុមការងារតាមផ្លូវរួមមាន:<br>១. សកម្មភាពតាមផ្លូវ និង សហគមន៍:<br>- បំណិនជីវិត : ១០៩,៧៣៣ ដង( ស្រី៣២,៩១២ដង) |

| | | |
|---|---|---|
| | | - ការព្យាបាលៈ ២៥,៧២២ដង( ស្រី៧,៩២២ ដង)<br>- សកម្មភាពកំសាន្តសប្បាយ : ៦២,៩៦៨ ដង ( ស្រី២២,៣២៣ ដង)<br>- ការកាត់បន្ថយភាពមានគ្រោះគ្រឿងញៀនតាមផ្លូវ:៧៦,៩៧៧ដង( ស្រី១៣,៣៤៥ដង)<br>២. មណ្ឌលសំចត<br>- ផ្ទះសំណាក់ពេលថ្ងៃ : ៣៤,៣១៩ដង ( ស្រី១១,២៣០ដង)<br>- ផ្ទះមិត្តភាពៈ ៦២,១២៨ ដង( ស្រី១៤,១៨២ ដង)<br>- មណ្ឌលសុវត្ថិភាពកុមារៈ ២៣,០៨០ ដង( ស្រី ១,១៩៣ដង)<br>- មណ្ឌលយុវវ័យឆ្លាតៈ ២៥,៦៧១ ដង( ស្រី៧,៧៣៥ ដង)<br>- មណ្ឌលខ្ញុំ និងអ្នកៈ ២០,៦៣៣ ដង( ស្រី ៧,៣៥ ដង)<br>- មណ្ឌលសហគមន៍អណ្តូងៈ ៥,៨៤៥ ដង( ស្រី២,៤៣៩ ដង)<br>- មណ្ឌលសំចតចល័តបក្សីឆ្លាតៈ ៣៥,៥៤៩ ដង( ស្រី ១២,៩៥០ដង)<br>៣. ការគាំទ្រគ្រួសាររស់នៅជាមួយមេរោគអេដស៍/ជម្ងឺអេដស៍<br>- សេវាចំនួន ៣,៧៧៦ ដង( ស្រី២,២៣៩ដង) បានផ្តល់ដល់ឪពុក/ម្តាយចំនួន ២២១នាក់ (ស្រី១៤១នាក់) ជាគ្រួសាររស់នៅជាមួយមេរោគអេដស៍/ជម្ងឺអេដស៍ ក្នុងនោះចំនួនសេវា ៥៨២ ដង (ស្រី ២៩៧ដង) បានផ្តល់ជូនកុមារ/ យុវវ័យចំនួន ៦០នាក់ (ស្រី៣០នាក់) ដែលបានចូលរួមការកិច្ចប្រជុំជាមួយក្រុមគាំទ្រមួយដងក្នុងមួយសប្តាហ៍នៅ ៤ តំបន់ ក្នុងមណ្ឌលសំចត ។<br>៤. មិត្តអប់រំមិត្ត<br>- មិត្តអប់រំមិត្តសរុបចំនួន ១៨៥ នាក់( ស្រី ៦៤នាក់) ថ្មីចំនួន ១០៣នាក់( ស្រី៣៤នាក់) ហើយ |

| | | |
|---|---|---|
| | | មិត្តអប់រំមិត្តចំនួន ២៥នាក់( ស្រី៧នាក់) បានបោះបង់។<br>- មិត្តអប់រំមិត្តនៅសល់សរុប ១៦០នាក់ ( ស្រី៥៧នាក់) បានបន្តការអប់រំស្តីពីសុខភាពបន្តពូជកាមរោគមេរោគអេដស៍/ជម្ងឺអេដស៍ និងគ្រឿងញៀនដល់ កុមារ/យុវវ័យចំនួន ១៤,៩០២ ដង ( ស្រី៦,០៧៥ ដង) ជាមួយគ្រួសារចំនួន ៥,១៦៨( ស្រី ២,០៦៧) ។<br>- ស្រោមអនាម័យសរុបចំនួន ១៩៤,៣៦៣ ស្រោម បានចែកចាយដល់ក្រុមគោលដៅតាមរយៈបុគ្គលិកមិត្តអប់រំមិត្ត និងភ្នាក់ងារសុវត្ថិភាព។<br>៥. ការបញ្ជូនៈ<br>- កុមារ/យុវវ័យតាមថ្នល់ និង សហគមន៍សរុបចំនួន ៨០១នាក់( ស្រី២៩៥នាក់) បានសំរេចចិត្តចាកចេញពីតាមថ្នល់ និងបញ្ជូនទៅរៀននៅមជ្ឈមណ្ឌលអប់រំចំនួន ៣៧៧នាក់ ( ស្រី១៩៦នាក់) និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ៤២៤នាក់( ស្រី៩៩នាក់) របស់អង្គការមិត្តសំឡាញ់។<br>- កុមារ/យុវវ័យ និងឪពុក/ម្តាយចំនួន ៤៥៧នាក់( ស្រី១១៧នាក់) បានគាំទ្រដើម្បីទទួលសេវាធ្វើតេស្តឈាមរកមេរោគ អេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់។<br>៦. គ្រឿងញៀន<br>ផ្ទះបៃតង គឺជាមជ្ឈមណ្ឌល ដែលមានកម្មវិធីព្យាបាល/បន្សាប និងស្តារនីតិសម្បទាមានទីតាំងស្ថិតនៅជាយរាជធានីភ្នំពេញ។មជ្ឈមណ្ឌលនេះទទួលស្វាគមន៍អ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកញៀនគ្រឿងញៀន ដែលចង់បោះបង់ចោលការប្រើប្រាស់គ្រឿងញៀនដើម្បីបន្សាប និងស្តារនីតិ សម្បទាតាមរយៈសេវាកម្មកាត់បន្ថយភាពគ្រោះថ្នាក់ដោយបានគាំទ្រ និងផ្តល់ដល់ពួក |

| | | |
|---|---|---|
| | | គេនៅតាមផ្លូវ និងសហគមន៍។<br><br>ចំនួនសេវាសរុប ១២៨,១១៩ ដង(ស្រីចំនួន ២៥,៥៩៧ដង) ក្នុងនោះមានកុមារ/យុវវ័យសរុប ចំនួន ២០៧ នាក់(ស្រី១៩នាក់) ជាអ្នកប្រើប្រាស់គ្រឿងញៀននៅតាមផ្លូវ និងសហគមន៍ រាប់បញ្ចូលអ្នកចាក់តាមសរសៃ សរុប ៤៤ នាក់ (ស្រី ៧នាក់) ដែលគាំទ្រឱ្យទទួលសេវាព្យាបាល/បន្សាប និង សេវាកាត់បន្ថយភាព គ្រោះថ្នាក់។<br><br>❷ **<u>មណ្ឌលស្នាក់នៅបណ្ដោះអាសន្ន</u>**<br>- ផ្ដល់សេវាសរុបចំនួន ៦៣០,០០០ ដង (ស្រីចំនួន១៣១,០៤០ ដង)ក្នុងនោះមានកុមារ/យុវវ័យជាមធ្យមក្នុងមួយ ខែសរុប ចំនួន ២៥០នាក់ (ស្រី៥២នាក់) ទទួលបានសេវាកម្មផ្សេងៗ ប្រកបដោយសុវត្ថិភាពពីមណ្ឌលស្នាក់នៅបណ្ដោះអាសន្នទាំងបួន ដូចជាៈ ការស្នាក់នៅ សម្ភារៈអនាម័យ អាហារ ការព្យាបាល បំណិនជីវិត សកម្មភាពកំសាន្តសប្បាយ និងដំណើរទស្សនកិច្ចសិក្សានៅខាងក្រៅ និងរៀនអក្សរ/ជំនាញនៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ។<br><br>ក៏ប៉ុន្តែនៅចុង ខែធ្នូ ឆ្នាំ២០១០ មណ្ឌលស្នាក់នៅបណ្ដោះអាសន្នទី ៣ ត្រូវបានផ្ទេរកុមារទៅមណ្ឌលស្នាក់នៅបណ្ដោះអាសន្ន ទី១ និងទី៤។ មណ្ឌលនីមួយៗអាចឱ្យកុមារស្នាក់នៅពី ៨០ នាក់ ទៅ១០០នាក់ លើកលែងតែមណ្ឌលស្នាក់នៅបណ្ដោះអាសន្នទី ២ អាចស្នាក់នៅពី៦០នាក់ ទៅ ៨០នាក់ ហើយមានមេផ្ទះ បុគ្គលិកសង្គម និងបុគ្គលិកពេទ្យសំរាប់គាំទ្រ និងមើលថែរក្សាកុមារ។<br><br>❸ **<u>គំរោងអប់រំ</u>**<br>- សេវាសរុបចំនួន ២០៦,០៩៧ ដង(ស្រីចំនួន៧០,៦១៥ដង) បានផ្ដល់ដល់កុមារ/យុវវ័យសរុបចំនួន |

| | | |
|---|---|---|
| | | ២,៧៩៦ នាក់( ស្រី៩២២នាក់) មកពីៈ<br>កុមារចំនួន ១,៩៥១នាក់( ស្រី ៧០៤នាក់) ទទួលបានការអប់រំក្រៅប្រព័ន្ធនៅតាមថ្នល់ សហគមន៍ និងមណ្ឌលនៃអង្គការមិត្តសំឡាញ់។<br>យុវវ័យចំនួន ៦៩៦( ស្រី១៧៤នាក់) បានរៀនជំនាញវិជ្ជាជីវៈ នៅជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នៃអង្គការមិត្តសំឡាញ់។<br>កុមារ/យុវវ័យខាងលើទាំងអស់នេះ រួមទាំងកុមារមកពីសហគមន៍ចំនួន ១០៩នាក់ ( ស្រី ៤៤នាក់) បានចូលរួមសកម្មភាពកំសាន្តសប្បាយផ្សេងៗទៀត ពីក្រុមវប្បធម៌ដូចជា សិល្បៈ គំនូរ កីឡា ទស្សនកិច្ចសិក្សា និងបណ្ណាល័យ។<br>- លើសពីនេះទៀតកុមារ/យុវវ័យទទួលបានសេវាអប់រំបន្ថែមទៀតរួមមានៈ អប់រំបំណិនជីវិត ពិគ្រោះយោបល់ ការដោះស្រាយបញ្ហា ផែនការណ៏អនាគតចំណេះដឹងអាជីវកម្ម ខ្នាតតូចការគាំទ្រផ្នែកសុខភាព ភាសាអង់គ្លេស និងជួយរកការងារធ្វើ បន្ទាប់បញ្ចប់ពីការសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈពីក្រុមការងារទាំងនៅភ្នំពេញ និងខេត្តកំពង់ចាម។<br>❹ **<u>សមាហរណកម្ម</u>**<br>- ផ្តល់សេវាសរុបចំនួន ១,១៨២ ដង( ស្រីចំនួន ៣៧៨ដង) ក្នុងនោះមានកុមារ/យុវវ័យសរុបចំនួន ១,៧២៣នាក់( ស្រី៧០៧នាក់) បានគាំទ្រនិងជួយជំរុញឱ្យត្រឡប់ទៅគ្រួសាររបស់ពួកគេ សាលារដ្ឋ និងផ្តល់ការងារតាមជំនាញ។ ក្រុមការងារក៏បានផ្តល់ការគាំទ្រដល់កុមារ និងគ្រួសារដើម្បីធ្វើសមាហរណកម្ម និងបន្តការតាមដានយ៉ាងទៀតទាត់ដើម្បីដំណើរការសមាហរកម្មទទួលបានជោគជ័យ។ |

| | | |
|---|---|---|
| | - ប្រវត្តិរបស់កុមារតាមផ្លូវ និងការស្រាវជ្រាវស្តី ពីបញ្ហាពាក់ព័ន្ធផ្សេងៗ ត្រូវបានបោះពុម្ពផ្សាយ ។ | • កម្រងឯកសារកុមារតាមផ្លូវ២០០៩ បានបញ្ចប់ និងចែកជូនដល់អង្គការដៃគូផ្សេងៗរួចរាល់ហើយ ។<br>- អ្នកគ្រប់គ្រងគម្រោងតាមផ្លូវ សហការជាមួយអ្នកសម្របសម្រួលគម្រោងគ្រឿងញៀនធ្វើការអង្កេតគ្រឿងញៀនឥតព្រៀងទុកប្រចាំឆ្នាំ ជាមួយកុមារ/យុវវ័យដែលកំពុងរស់នៅ និងធ្វើការនៅតាមផ្លូវ ។ សរុបកុមារ/យុវវ័យចំនួន ៣,៦៨៩ នាក់(ស្រី១,៣១២នាក់) ត្រូវបាន សម្ភាសន៏នាថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១០ ។<br>- អ្នកគ្រប់គម្រោងតាមផ្លូវ បានសហការជាមួយបណ្តាញអ្នកធ្វើការងារជាមួយកុមារតាមផ្លូវនៅកម្ពុជាបានធ្វើការអង្កេតឥតព្រៀងទុកប្រចាំឆ្នាំជាមួយកុមារ/យុវវ័យ ដែលកំពុងរស់នៅ និងធ្វើការនៅតាមផ្លូវ និងសហគមន៏ ។ សរុបកុមារ/យុវវ័យចំនួន ២,៤០០នាក់ (ស្រី៧៦៧នាក់) ត្រូវបានសម្ភាសន៏ នាថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១០ ។ |
| | -កម្មវិធី និងគំរោងត្រូវបានវាយតំលៃ និងតាមដានជាបន្តបន្ទាប់ ដើម្បីធានានូវការអនុវត្តន៏ ដែលល្អបំផុត ។ | • អប់រំក្រៅប្រពន្ធ័នៃគម្រោងអប់រំ ត្រូវបានទស្សនកិច្ច និងវាយតម្លៃដោយម្ចាស់ជំនួយមូស្លីមអេដកម្ពុជាដើម្បីតាមដានពីដំណើរការណ៏គម្រោង នាថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១០ និងធ្វើបទបង្ហាញពីសកម្មភាពលទ្ធផលបញ្ហាជួបប្រទះ បទពិសោធន៏ និងអនុសាសន៏ដើម្បីកែលំអសំរាប់គម្រោងពេលក្រោយទៀត នាថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១០ ផងដែរ ។<br>- អ្នកគ្រប់គ្រងគម្រោងសហភាពអឺរ៉ុប បានទស្សនកិច្ច និងវាយតម្លៃតាមដានពីដំណើរការគម្រោងនៅខេត្តកំពង់ចាម នាថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០១០ ។<br>- អ្នកវាយតម្លៃខាងក្រៅរបស់គម្រោង (CCFD/EU) បានវាយតម្លៃគម្រោងលើកទី៣ ដើម្បីធ្វើការតាមដានពីដំណើរការគម្រោង បន្ទាប់ពីបានធ្វើការវាយតម្លៃចុងក្រោយចំនួន ២លើក នាថ្ងៃទី ១៥-៣០ ខែមីនា ឆ្នាំ២០១០ ។ |

| | | |
|---|---|---|
| | | - មន្ត្រីគម្រោង CCFD មកពីមកប្រទេសបារាំងបានមកទស្សនកិច្ច និងវាយតម្លៃពីដំណើរការណ៏គម្រោង នៅភ្នំពេញ នាថ្ងៃទី ៣០-៣១ ខែ សីហា ឆ្នាំ ២០១០។<br>- មន្ត្រីអង្គការ Planet Wheeler បានមកទស្សនកិច្ចគម្រោងដើម្បីធ្វើឱ្យគម្រោងដំណើរឱ្យកាន់តែមានប្រសិទ្ធិភាព នៅភ្នំពេញ នាថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០។<br>- ហ្វ្រេន្ឌអ៊ិនធីណាសិនណល បានធ្វើការវាយតម្លៃគម្រោងតាមផ្ទះរបស់អង្គការមិត្តសំឡាញ់ ដើម្បីតាមដាននិងពង្រឹងគុណភាពសេវាកម្មនៃក្រុមការងារតាមផ្ទះ នាខែ ធ្នូ ឆ្នាំ ២០១០។ |
| | -ក្រុមការងារទទួលបានការបណ្តុះបណ្តាលជាបន្តបន្ទាប់ និងគាំទ្របច្ចេកទេស។ | • ក្នុងឆ្នាំនេះ ជាមធ្យមបុគ្គលិកទាំងអស់បានទទួលការបណ្តុះបណ្តាលចំនួន ២ ដង ដែលមានបុគ្គលិកសរុបចំនួន៥២០នាក់ (ស្រី ២២១នាក់) បានទទួលការបណ្តុះបណ្តាលខាងក្នុង ផ្តល់ដោយមិត្តសំឡាញ់ និងហ្វ្រេន្ឌអ៊ិនធីណាសិនណល លើប្រធានបទផ្សេងៗ ដូចជា: ការថែ ទាំជំនួស មូលដ្ឋានគ្រឹះនៃការប្រើប្រាស់គ្រឿងញៀន ការគ្រប់គ្រងករណី ការរំលឹកពីគោលនយោបាយការពារកុមារ ទំនាក់ទំនងនៃការធ្វើការជាក្រុម ការបង្កើតសកម្មភាពកំសាន្ត ទំរង់បន្ថែម សំរាប់អ្នករស់នៅជាមួយមេរោគអេដស៏/ជម្ងឺអេស៏ សង្គ្រោះបឋម ការបង្រៀននិង ការតាមដាន សុខភាពបន្តពូជ កាមរោគ មេរោគអេដស៏/ជម្ងឺអេដស៏ បច្ចេកទេសនៃការសិក្សា វិធីសាស្រ្តលើការ ធ្វើការជាមួយកុមារតាមផ្ទះ សុខភាពមាត់ធ្មេញ និងច្បាប់រលូតកូន និងវគ្គបណ្តុះបណ្តាលអ្នក អប់រំលើការធ្វើការជាមួយកុមារតាមផ្ទះ។<br>• លើសពីនេះទៀតមានបុគ្គលិក ៨០នាក់ (ស្រី៤០នាក់) បានទទួលការបណ្តុះបណ្តាលនៅខាងក្រៅ ដែលផ្តល់ការគាំទ្រថវិកាពីម្ចាស់ជំនួយ និងអង្គការដៃគូផ្សេងៗ លើប្រធានបទ: មេតាដូន ការតស៊ូមតិ ក្មេងប្រុសជាចំបង ការគ្រប់គ្រងអាជីវកម្ម ភាសាអង់គ្លេសទូទៅ អភិបាលកិច្ច |

| | | |
|---|---|---|
| | | ការអភិវឌ្ឍន៍ក្រុមប្រឹក្សាភិបាល ការគ្រប់គ្រងភោជនីយដ្ឋាន ការគ្រប់គ្រង់ហិរញ្ញវត្ថុផ្ទៃក្នុងសិក្សាកម្មវិធីកុំព្យូទ័រ ឃ្វីកប៊ុក និង ការគ្រប់គ្រង់បុគ្គលិក ។ |
| ១.៣ គាំទ្រដល់កុមារ/យុវវ័យ តាមផ្លូវ ១,០០០ នាក់ក្នុងមួយឆ្នាំក្នុងការបញ្ជូនកុមារទៅរួមរស់ក្នុងសង្គមវិញ( គ្រួសារនិង/ឬសាលារៀន ឬ ការងារ និងជាមួយប្រជាពលរដ្ឋល្អ) និងតាមដានកុមារនិងយុវវ័យតាមផ្លូវ ២,៥០០នាក់បន្ថែមទៀត ដែលបានគាំទ្រពីមុនមក។ | -កុមារ ៣៥០ នាក់ ត្រូវបានបញ្ជូនទៅចូលរៀនក្នុងសាលារដ្ឋ ក្នុងមួយឆ្នាំនៅត្រីមាសទី៤នៃឆ្នាំ ២០១១។<br>-កុមារ ១៥០០ នាក់ ត្រូវបានជួយគាំទ្រឱ្យនៅរៀនក្នុងមួយឆ្នាំ នៅត្រីមាសទី៤ នៃឆ្នាំ ២០១១ ។<br>- យុវវ័យតាមផ្លូវ ១៥០នាក់ រកការងារបានធ្វើក្នុងមួយឆ្នាំនៅត្រីមាសទី៤ នៃឆ្នាំ ២០១១។<br>- កុមារ/យុវវ័យតាមផ្លូវ ១.០០០ នាក់ ត្រូវបានធ្វើសមាហរណកម្មទៅរួមរស់ក្នុងសហគមន៍វិញ/គាំទ្រចូលទៅ ក្នុងគ្រួសារ ( គ្រួសារផ្ទាល់/គ្រួសារសាច់ញាតិ/ គ្រួសារ | • កុមារចំនួន ១,១១០នាក់ ( ស្រី៤៨២នាក់) ត្រូវបានបញ្ជូនទៅចូលរៀនក្នុង សាលារដ្ឋ រួមបញ្ចូលទាំងសិស្សថ្មី ៣៨៥នាក់( ស្រី១៧២នាក់) បានបន្តជួយគាំទ្រសម្ភារៈសិក្សា និងបន្តការចុះតាមដានសួរសុខទុក្ខយ៉ាង ទៀងទាត់ទាំងនៅរាជធានីភ្នំពេញ និង បណ្តាខេត្តនានា។<br>• កុមារចំនួន ១៦៥នាក់ (ស្រី៤៦នាក់) ត្រូវបានដាក់អោយមានការងារធ្វើ និងប្រកបការងារដោយខ្លួនឯង ក្នុងនោះមានសិស្សចំនួន ៩៤ នាក់( ស្រី ១៧នាក់) បានបញ្ចប់កម្មវិធីសិក្សាដោយជោគជ័យ និងសិស្សខ្លះទៀតបានសំរេចចិត្តចាកចេញមុនពេល ដើម្បីស្វែងរកការងារធ្វើ និងប្រើប្រាស់ជំនាញដែលពួកគេមានស្រាប់។<br>- ១០៨ នាក់( ស្រី ៣៤នាក់) ត្រូវបានដាក់ឱ្យធ្វើការនៅតាមហាង ។<br>- ៥៧នាក់ ( ស្រី ១២នាក់) ត្រូវបានដាក់ឱ្យរកស៊ីដោយខ្លួនឯង។<br>• កុមារ/យុវវ័យតាមផ្លូវ ៦៦០នាក់ (ស្រី២៣៧នាក់) ត្រូវបានធ្វើសមាហរណកម្មទៅគ្រួសាររស់នៅ ឯករាជ្យ រួមបញ្ចូលទៅធ្វើការ និងសាលារដ្ឋ។<br>១. កុមារ/យុវវ័យចំនួន ៥៧៦នាក់ ( ស្រី ២១៧នាក់) បញ្ជូនទៅគ្រួសារពួកគាត់ផ្ទាល់<br>- ១០៩នាក់( ស្រី៣១នាក់) ត្រូវបានដាក់អោយមានការងារធ្វើ។ |

| | | |
|---|---|---|
| | ធមិ រួមទាំងចូលសាលាឬធ្វើការ) ក្នុងមួយឆ្នាំនៅត្រីមាសទី៤នៃឆ្នាំ២០១១។ | - ៨២នាក់ (ស្រី១៤នាក់) ទទួលបានការគាំទ្រ និងការធ្វើសមាហរណកម្មភ្លាម១ បន្ទាប់ពីផ្សះផ្សាគ្រួសាររួច ។<br>- ៣៨៥ (ស្រី១៧២ នាក់) សមាហរណកម្មទៅសាលារដ្ឋ ក្នុងនោះមាន ៣៤ នាក់(ស្រី១០ នាក់) មកពីខេត្ត។<br>២.កុមារ/យុវវ័យចំនួន ៣៧នាក់(ស្រី៨នាក់) ត្រូវបានបញ្ជូនទៅគ្រួសារសាច់ញ្ញាតិ ។<br>- ១០នាក់(ស្រី ២នាក់) បញ្ជូនទៅធ្វើការរកស៊ីដោយខ្លួនឯង។<br>- ២១នាក់ (ស្រី៤នាក់) បានការគាំទ្រ និងធ្វើសមាហរណកម្មភ្លាម១។<br>- ៦ នាក់(ស្រី២ នាក់) បានបញ្ជូនទៅកាន់គ្រួសារធមិរយៈពេលខ្លីនៅខេត្តកណ្ដាល និងភ្នំពេញ ។<br>៣.កុមារ/យុវវ័យ៤៦ នាក់(ស្រី ១២នាក់) ត្រូវបានបញ្ជូនទៅរស់នៅដោយឯករាជ្យ និងរកការងារធ្វើដោយខ្លួនឯង។<br>៤. យុវវ័យចំនួន ១នាក់ ត្រូវបានសមារណកម្មទៅអង្គការកម្មវិធីអភិវឌ្ឍន៍សំរាប់ជនពិការនៅខេត្តកំពង់ចាម។ |
| | - កុមារ/យុវវ័យតាមផ្ទះ ចំនួន ១.០០០ នាក់ ដែលមិត្តសំឡាញ់ត្រូវបានឧបត្ថម្ភដល់គ្រួសារក្នុងមួយឆ្នាំ នៅត្រីមាសទី៤ នៃឆ្នាំ ២០១១។ | • កុមារ/យុវវ័យសរុប ៦១៣ នាក់(ស្រី២២៥នាក់) បន្តជួយឧបត្ថម្ភឱ្យស្នាក់នៅក្នុងគ្រួសារតាមរយៈការផ្ដល់ការប្រឹក្សាយោបល់ដោះស្រាយបញ្ហាគ្រួសារ គាំទ្រអាជីវកម្មខ្នាតតូច សិប្បកម្មតាមផ្ទះ ការព្យាបាល មធ្យោបាយ ធ្វើដំណើរ អាហារ ទឹកដោះគោ និង ជួលផ្ទះឱ្យស្នាក់នៅនៅភ្នំពេញ និងបណ្ដាញខេត្តនានា។ |
| | -តាមដានកុមារ និងយុវវ័យតាមផ្ទះ ២,៥០០ នាក់បន្ថែមទៀត ដែលបានគាំទ្រ | • សរុបចំនួនសួរសុខទុក្ខកុមារ ១៣,៩៩៩ដង (ស្រី៥,៥០៤ដង) ដែលបានធ្វើជាមួយកុមារចំនួន ១,៧២៣នាក់ (ស្រី៧០៧នាក់) នៅគ្រួសារ កន្លែងធ្វើការរបស់ពួកគេ ដើម្បីតាមដានពីស្ថានភាព |

| | | |
|---|---|---|
| | ពីមុនមក។<br><br>- កុមារ/យុវវ័យតាមផ្ទាល់ ៥០ នាក់ ក្នុងមួយ ឆ្នាំត្រូវបានចុះបញ្ជីផ្លូវច្បាប់/ធ្វើនីតិកម្ម (អត្តសញ្ញាណប័ណ្ណសំបុត្រកំណើតចុះឈ្មោះបោះឆ្នោត តាមការចាំបាច់) ក្នុងនាមជាពលរដ្ឋកម្ពុជាក្នុងមួយឆ្នាំនៅឆ្នាំ ២០១១។ | ពួកគេនិងសុខុមាភាពបន្ទាប់ពីសមាហរកម្ម ។ការសួរសុខទុក្ខធ្វើឡើងនៅបណ្តាលខេត្តនានាក្រោមកិច្ចសហការណ៍ពីមន្ទីរសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទាខេត្ត។<br>• កុមារ/យុវវ័យចំនួន១៩នាក់(ស្រី១០នាក់)ទទួលបានអត្តសញ្ញាណប័ណ្ណ ១០នាក់(ស្រី៧ នាក់) សំបុត្រកំណើតដោយស្របច្បាប់ចំនួន ៥នាក់(ស្រី៣នាក់) និងចុះឈ្មោះបោះឆ្នោតចំនួន ៤នាក់។ |
| ១.៤ ចូលរួមយ៉ាងខ្លាំងក្លាជាមួយសេវាកម្ម ដែលពាក់ព័ន្ធរបស់រដ្ឋាភិបាល/អាជ្ញាធរនៅក្នុងគម្រោង។ | -អាជ្ញាធរជាតិត្រូវបានទទួលជ្រាប និងចូលរួម យ៉ាងសកម្មនៅក្នុងកម្មវិធី។ | <u>ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា</u><br>- បានចូលរួមប្រជុំជាមួយសង្គមកិច្ច ដើម្បីចែករំលែកពតិមានអំពីការធ្វើសមាហរកម្មកុមារនិងពង្រឹងកិច្ចសហការ រវាងអង្គកាមិត្តសំឡាញ់ និងក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិ សម្បទា ។<br>- អ្នកឯកទេសបំណិនជីវិតបានចូលរួមប្រជុំស្តីពីកុមារដែលងាយរងគ្រោះ និងកុមារកំព្រានៅក្រសួងសង្គមកិច្ច អតីត យុទ្ធ ជន និងយុវនីតិសម្បទា នាថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១០។<br>- បានចូលរួមសិក្ខាសាលាស្តីពីច្បាប់ស្តីពីសុំកូនធចិញ្ចឹម នៅសណ្ឋាគារណាហ្គាវើល នាថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១០ រៀបចំដោយក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា។<br>- បានចូលរួមកិច្ចប្រជុំជាមួយក្រសួងសង្គមកិច្ច និងអង្គការដៃគូដទៃទៀតចំនួន ៦ដង ស្តីពីកម្មវិធីសមាហរណកម្ម ដើម្បីចែករំលែកពតិមានស្តីពីការគ្រប់គ្រងករណី និងដោះស្រាយបញ្ហានៅពេលជួបប្រទះ ។ |

| | | |
|---|---|---|
| | | - បុគ្គលិកមិត្តសំឡាញ់ចំនួន ៣នាក់ បានចុះសួរសុខទុក្ខកុមារ/យុវវ័យនៅមជ្ឈមណ្ឌលសង្គមកិច្ចចំនួន ២ដង នា ថ្ងៃទី ០៤ ខែមិថុនា និង ថ្ងៃទី ៤ខែ កក្កដាឆ្នាំ២០១០។<br>- បុគ្គលិកមិត្តសំឡាញ់ សហការជាមួយមន្ទីរសង្គមកិច្ចលើការងារសមាហរណកម្មកុមារទៅក្នុងសង្គម ក្នុងនោះមាន ខេត្តកណ្តាល កំពង់ស្ពឺ និងខេត្តបាត់ដំបង ដែលមានមន្ត្រី ២៥នាក់ សហការអនុវត្តគម្រោងនេះ។ កម្មវិធីនេះគាំទ្រដោយអង្គការអង្គការមូលនិធិកុមារសហប្រជាជាតិ។<br>- អ្នកគ្រប់គ្រងគម្រោង និងអ្នកគ្រប់គ្រង់ករណី បានផ្តល់ការបណ្តុះបណ្តាលចំនួន ២ ដង លើប្រព័ន្ធគ្រប់គ្រងករណី និងវិធីប្រើប្រាស់ទំរង់មិត្តសំឡាញ់ ដល់បុគ្គលិកសង្គមកិច្ចមកពីខេត្តបាត់ដំបង កំពង់ស្ពឺ និងខេត្តកណ្តាល នាថ្ងៃទី ៦-៨ ខែកញ្ញា ឆ្នាំ ២០១០ និង ថ្ងៃទី ២២-២៤ ខែកញ្ញា ឆ្នាំ២០១០ នៅប្រៀន្សអ៊ិនធើណាសិនណល មុននឹងផ្ទេរករណីនេះជូនទៅពួកគាត់។<br>- បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងការធ្វើសមាហរណកម្ម និងការតាមដាននៅខេត្តព្រះសីហនុ រៀបចំដោយក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា នាថ្ងៃទី ១៩-២១ ខែតុលា ឆ្នាំ២០១០។<br>- បានចូលរួមសិក្ខាសាលាលើការជួញដូរកុមារនិង ស្ត្រីពីប្រទេសកម្ពុជាទៅប្រទេសវៀតណាម និងពីប្រទេសវៀតណាម ទៅប្រទេសកម្ពុជា នៅខេត្តសៀមរាប នាថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០ រៀបចំដោយក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា។<br>- បានចូលរួមកិច្ចប្រជុំចំនួន ២ដងជាមួយក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទាដើម្បីកែតំរូវលើបទដ្ឋានអប្បរមាសម្រាប់ការថែទាំ លើការជួញដូរកុមាររងាយរងគ្រោះ នៅក្នុងមណ្ឌល។<br>- វិញ្ញាបនប័ត្របញ្ជាក់ការសិក្សាចំនួន ៩៤ ពីជំនាញវិជ្ជាជីវៈ និងអាជីវកម្មខ្នាតតូចត្រូវបានចុះហត្ថលេខាទទួលស្គាល់ដោយ ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទាហើយបានចែកជូន |

| | | |
|---|---|---|
| | | ដល់សិស្សទាំងអស់ ។<br>- បានផ្តល់បទបង្ហាញដល់ជនបង្គោលរបស់ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទាចំនួន ៣ ដង ស្តីពីបទបង្ហាញពីបទពិសោធន៍លើនិតិវិធីបណ្តឹងរបស់កុមារនៅក្នុងមណ្ឌលនៅភ្នំពេញ កំពង់ស្ពឺ និង សៀមរាប ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីបទដ្ឋានអប្បរមាសម្រាប់ការថែទាំការគាំទ្រ និងការការពារចំពោះកុមារ ចំពោះកុមារកំព្រា និងកុមារងាយរងគ្រោះ ឆ្នាំ២០១១-២០១៥ នៅសណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ នាថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។<br><br><u>ក្រសួងអប់រំ យុវជន និង កីឡា/ វិទ្យាស្ថានជាតិអប់រំ</u><br>- អ្នកបច្ចេកទេសអប់រំក្រៅប្រពន្ធ័បានកិច្ចសហការយ៉ាងជិតស្និតជាមួយវិទ្យាស្ថានជាតិអប់រំ និង ការិយាល័យអប់រំក្រៅប្រពន្ធ័ ដើម្បីបង្កើតឧបករសិក្សា។ សៀវភៅឧបករណ៏សិក្សា ( Tool Box) បានរៀបចំរួចរាល់ ក្នុងនោះ មានសំភារៈអប់រំតាមរយៈប័ណ្ណរូបភាពសំរាប់គ្រូបង្រៀន ដើម្បី ឆ្លើយតបក្នុងការសិក្សារបស់ កុមារទៅលើការរៀនអក្សរ គណិតវិទ្យា និងវិទ្យាសាស្រ្ត។ សរុប សកម្មភាពចំនួន ៦០ ដែលបានបង្កើតនៅក្នុងប័ណ្ណរូបភាពទៅលើ ៣ មុខវិជ្ជារួមមានៈ អក្សរ ១៩ ប័ណ្ណរូបភាព គណិតវិទ្យា ២៤ បណ្ណ័រូបភាព និង វិទ្យាសាស្រ្ត១៧ បណ្ណ័រូបភាព។ សៀវភៅឧបករណ៏សិក្សានេះត្រូវបានឯកភាពដោយក្រសួងអប់រំ យុវជន និងកីឡា នាថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១០ ។<br>- បានចូលរួមគណៈកម្មការក្នុងកិច្ចពិគ្រោះយោបល់លើរបាយការណ៏ស្រាវជ្រាវ ម៉ារ៉ា រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា នាថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១០ ។ |

| | | |
|---|---|---|
| | | - បានរៀបចំកិច្ចប្រជុំជាមួយអ្នកចូលរួមមកពីសាលារដ្ឋនិងអង្គការដៃគូចំនួន២៤នាក់( ស្រី០៤នាក់) ស្តីពីការប្រកួតប្រជែងគូរគំនូរក្រោមប្រធានបទសមភាពយេនឌ័រ ក្រោមការឧបត្ថម្ភពីសហភាពអឺរ៉ុបតាមរយៈអង្គការមិត្តសំឡាញ់។<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ១៨នាក់( ស្រី១២នាក់) បានចូលរួមសកម្មភាពធ្វើតេស្តទៅលើការប្រើប្រាស់សៀវភៅឧបករណ៍សិក្សា (Tool Box)ជាមួយកុមារទាំងនៅតាម ថ្នល់ និងមណ្ឌលដែលសំរបសំរួលដោយវិទ្យាស្ថានជាតិអប់រំ និងអ្នកឯកទេសអប់រំក្រៅប្រពន្ធ័ អង្គការមិត្តសំឡាញ់ ដើម្បីធ្វើឱ្យប្រាកដថាឧបករណ៍សិក្សានេះប្រកបដោយគុណភាពល្អ។<br>- បានចូលរួមកិច្ចប្រជុំជាមួយដៃគូអប់រំស្តីពីផែនការណ៍ការងារសំរាប់ទិវាអក្ខរកម្មអន្តរជាតិ ដែលបានប្រព្រឹត្តនៅខេត្តបាត់ដំបង។<br>- អ្នកសម្របសម្រួលហ៊ីវ/អេដស៍បានចូលរួមកិច្ចប្រជុំជាមួយក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការសម្ពោធន៍ជាផ្លូវការនៃគណៈកម្មាធិការអន្តរមន្ទីរលើមេរោគអេដស៍ និងគ្រឿងញៀន នាថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១០។<br>- បុគ្គលិកមិត្តសំឡាញ់ចំនួន ២នាក់ បានចូលរួមទិវាអក្ខរកម្មអន្តរជាតិ ក្រោមប្រធានបទៈ អក្ខរកម្មជាសិទ្ធិជាមូលដ្ឋាន នៅខេត្តកំពង់ធំ ដោយអញ្ជើញចូលរួមដោយក្រសួងអប់រំ យុវជន និង កីឡា នា ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១០។<br>- អ្នកគ្រប់គ្រងគម្រោងអប់រំបានចូលរួមកិច្ចប្រជុំជាមួយការិយាល័យអប់រំក្រៅប្រព័ន្ធស្តីពីការចែករំលែកការងារអប់រំក្រៅប្រព័ន្ធ នាថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០។<br>- បានរៀបចំកិច្ចប្រជុំរវាងមិត្តសំឡាញ់ និង នាយកសាលា នាយករង គ្រូចំនួន ៣៧២ នាក់ មកពីសាលារដ្ឋទាំងនៅភ្នំពេញ និងកំពង់ចាមចំនួន ៥៧ សាលា។ គោលបំណងដើម្បីបង្កើនការទំនាក់ |

| | | |
|---|---|---|
| | | ទំនងការងារ ធ្វើសមាហរណកម្មកុមារ ទៅសាលារដ្ឋព្រមទាំងឱ្យពួកគាត់ស្គាល់ពីសកម្មភាពរបស់អង្គការមិត្តសំឡាញ់ រួមបញ្ចូលទាំងដំណើរការធ្វើសមាហរណកម្ម ។<br>- បានធ្វើកិច្ចសហការល្អជាមួយការិយាល័យអប់រំក្រៅប្រព័ន្ធខ័ណ្ឌ និងមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាចំនួន ៧១ សន្លឹកត្រូវបានចុះហត្ថលេខាទទួលស្គាល់ ដោយការិយាល័យអប់រំក្រៅប្រព័ន្ធ នៃមន្ទីរអប់រំ យុវជន និងកីឡា និងបានចែកចាយដល់សិស្សដែល បានប្រឡងជាប់អក្ខរកម្ម ដោយជោគជ័យនៅក្នុងមជ្ឈមណ្ឌលវិជ្ជាជីវៈ ។<br>- អ្នកឯកទេសអប់រំក្រៅប្រព័ន្ធ បានចូលរួមកិច្ចប្រជុំស្តីពីការធ្វើផែនទីអប់រំក្រៅប្រព័ន្ធ ដែលរៀបចំដោយភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល នៅណាហ្គាវើល នាថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០ ។<br>- អ្នកឯកទេសអប់រំក្រៅប្រព័ន្ធបានចូលរួមកិច្ចប្រជុំលើផែនការណ៍ប្រតិបត្តិការប្រចាំឆ្នាំ ដែលរៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា នៅសណ្ឋាគារ Imperial នាថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១០ ។<br><u>ក្រសួងសុខាភិបាល/អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន/អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍</u><br>- បានចូលរួមសិក្ខាសាលាស្តីពីការពង្រីកការថែទាំបន្ត និងប្រជុំពិគ្រោះយោបល់អាស៊ីលើកទី២ ស្តីពីការឆ្លើយតបទូលំទូលាយហួសពីព្រំដែនពាក់ពន្ធ័មេរោគអេដស៍/ជម្ងឺអេដស៍ នៅទីក្រុងបាងកក ប្រទេសថៃ នាថ្ងៃទី ១៧-២៣ ខែមករា ឆ្នាំ ២០១០ ។<br>- បានចូលរួមសិក្ខាសាលាស្តីពីការពង្រឹងច្បាប់ និងដៃគូដ៏មានប្រសិទ្ធិភាពលើការការកាត់បន្ថយភាពមានគ្រោះគ្រឿងញៀនតាមថ្នល់ នាថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១០ រៀបចំដោយវិទ្យាស្ថានសំរាប់សុខភាពពិភពលោក ម៉ែលប៊ិន ប្រទេសអូស្រ្តាលី ។<br>- អាជ្ញាប័ណ្ណកម្មវិធីម្ហុល/សីរ៉ាំងនៃអង្គការមិត្តសំឡាញ់ ត្រូវបានផ្តល់សារជាថ្មីពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនទៅដល់អង្គការមិត្តសំឡាញ់ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១១ ។ |

| | | |
|---|---|---|
| | | - បានចូលរួមក្នុងការរៀបចំផ្តួចផ្តើមឱ្យមានការព្យាបាល ឱសថជំនួសមេតាដូន នៅក្នុងប្រទេសកម្ពុជា ដែលដឹកនាំដោយក្រសួងសុខាភិបាល ក្រោមការគាំទ្រពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អង្គការសុខភាពពិភពលោក ជំនួយអង្គការសហប្រជាជាតិ អង្គការនៅក្នុងស្រុក និងអន្តរជាតិ ផ្សេងទៀត។ អ្នកសម្របសម្រួលកម្មវិធីគ្រឿងញៀននៃអង្គការមិត្តសំឡាញ់ត្រូវ បានទទួលស្គាល់ជាសមាជិក នៃក្រុមការងារបច្ចេកទេសលើការព្យាបាលឱសថជំនួនមេតាដូន (MMTTWG) និងផ្តល់ជាយោបល់តាមរយៈការប្រជុំ និងការពិភាក្សានេះ។<br>- ការព្យាបាលឱសថជំនួសមេតាដូន (MMT) បានចាប់ផ្តើមនៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១០ នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ដំណើរការដោយក្រសួងសុខាភិបាល ជាមួយការគាំទ្រដោយ អង្គការសុខភាពពិភពលោក អង្គការសុខភាពគ្រួសារអន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ថ្មីៗ នេះ មាន យុវវ័យចំនួន៤ នាក់ នៅក្នុងសហគមន៏បានទទួលការព្យាបាលឱសថជំនួសមេតាដូន នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ហើយកំពុងសិក្សាជំនាញនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលនៃអង្គការមិត្តសំឡាញ់ ។<br>- បានចូលរួមប្រជុំប្រចាំត្រីមាសយ៉ាងទៀងទាត់ ជាមួយក្រុមការងារទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេសដ៏ពាក់ព័ន្ធនឹងគ្រឿងញៀន (DHA) លើសពីនេះទៅទៀត អង្គការមិត្តសំឡាញ់ក៏ត្រូវបានគេបញ្ចូលជាសមាជិកសកម្មនៃ (DHA) ដឹកនាំដោយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និងបានរៀបកិច្ចប្រជុំប្រចាំខែពាក់ព័ន្ធជាមួយការបង្កើតមុខងាររបស់ទីប្រឹក្សា សំរាប់ការត្រួតពិនិត្យមើលលើផែនការណ៏យុទ្ធសាស្ត្រថ្នាក់ជាតិនៃក្រុមការងារទប់ស្កាក់មេរោគអេដស៏/ជម្ងឺអេសដ៏ពាក់ព័ន្ធនឹងគ្រឿងញៀនរបស់ក្រុម DHA ២០០៨-២០១០ និងការបង្កើតមុខងារសំរាប់អនុក្រុមការងារលើការតាមដាន និងវាយតម្លៃ និងអនុក្រុមការងារ |

| | | |
|---|---|---|
| | | លើគ្រឿងញៀន និងមេរោគអេដស៍/ជម្ងឺអេដស៍ ក្នុងការថែរក្សាមាជិកក្រុម DHA មិនអោយដាច់ពីគ្នា។<br>- បានចូលរួមការពិគ្រោះយោបល់ថ្នាក់ជាតិលើការពិនិត្យឡើងវិញនៃកម្មវិធីម្ជុល/សុឺរ៉ាំងលើកទី២ និងការអភិវឌ្ឍន៍នៃកម្មវិធីម្ជុល/សុឺរ៉ាំងលើកទី៣ នៅសណ្ឋាគារកាំបូឌីយ៉ាណា ភ្នំពេញ នាថ្ងៃទី ២៩-៣០ ខែមេសា ឆ្នាំ២០១០។<br>- បានចូលរួមកិច្ចប្រជុំ ក្រុមការងារធ្វើការជាមួយអ្នកប្រើប្រាស់គ្រឿងញៀន រៀបចំដោយហ្វ្រេន្ឋ អ៊ិនធឺណាសិនណាលអស់រយៈពេល២ថ្ងៃ និងបានអញ្ជើញដើម្បីធ្វើបទបង្ហាញលើការទំនាក់ទំនងល្អរវាងដៃគូរ និងបណ្តាញ CYTI នាថ្ងៃទី ២៩ ខែ មិថុនាឆ្នាំ២០១០។<br>- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ក្នុងគម្រោង Treatnet សំរាប់ការព្យាបាលគ្រឿង ញៀនតាមសហគមន៍ រៀបចំដោយ ការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម អង្គការ សុខភាពពិភពលោក UNAIDS និងអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ នាថ្ងៃទី៤ ខែមិថុនា ឆ្នាំ ២០១០។<br>- បានចូលរួមកិច្ចពិភាក្សា លើការត្រួតពិនិត្យលើគោលនយោបាយថ្នាក់ជាតិ និងគោលការណ៍នៃកម្មវិធីកម្មវិធីម្ជុល/សុឺរ៉ាំងរៀបចំដោយអង្គការសុខភាពពិភពលោក នាថ្ងៃទី៩ ខែកក្កដា ឆ្នាំ ២០១០។<br>- បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ១០២ ក្រោមប្រធានបទ " តើគ្រួសារចូលរួមក្នុងបញ្ហាគ្រឿងញៀនដោយរបៀបណា" នាថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១០។<br>- បានចូលរួមកិច្ចប្រជុំជាមួយ អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ដើម្បីចាត់វិធានការលើបញ្ហាសុខភាពសំរាប់គ្រួសាររស់នៅជាមួយមេរោគអេដស៍/ជម្ងឺអេដស៍នាថ្ងៃទី២០ខែកញ្ញា ឆ្នាំ ២០១០។<br>- បានចូលរួមកិច្ចប្រជុំជាមួយលេខាធិការដ្ឋាននៃក្រុមការងារទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេដស៍ |

| | | |
|---|---|---|
| | | ពាក់ព័ន្ធនឹងគ្រឿងញៀន(DHA) ដើម្បីពិភាក្សាលើការប៉ាន់ប្រមាណ និងសិក្សាកម្មវិធីម្ជុល/ស៊ីរ៉ាំង លើចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមនៃកម្មវិធីកម្មវិធីម្ជុល/ស៊ីរ៉ាំង និងស្វែងរកយុទ្ធសាស្ត្រដើម្បីពង្រឹងគំរូដែលមានស្រាប់សំរាប់កម្មវិធីម្ជុល/ស៊ីរ៉ាំងនៅទូទាំងប្រទេសកម្ពុជានៅអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ នាថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១០ ។<br>- បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ ១០៨ ក្រោមប្រធានបទស្តីពី ថាតើគ្រឿងញៀនពាក់ព័ន្ធជាមួយមេរោគអេដស៍/ជម្ងឺអេដស៍ ដោយរបៀបណា និង តើយើងអប់រំពួកគេដោយរបៀបណា? នាថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១០ ។ |
| | -មន្ទីរខេត្តដែលពាក់ព័ន្ធ ត្រូវបានចូលរួមនៅក្នុងគម្រោងជាបន្តបន្ទាប់ ។ | <u>កិច្ចសហការជាមួយអាជ្ញាធរក្នុងស្រុក អង្គការដៃគូ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត :</u><br>- បុគ្គលិកតាមផ្ទល់បានចូលរួមកិច្ចប្រជុំជាមួយសាលាក្រុងភ្នំពេញស្តីពី ការពង្រឹងគុណភាពបរិស្ថាននៅទីក្រុងភ្នំពេញ នាថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១០ ។<br>- បុគ្គលិកតាមផ្ទល់បានចូលរួមសិក្ខាសាលាជាមួយសមាគមកុមារកម្ពុជាប្រឆាំងទុរិភិក្ស និងហិង្សា (ស៊ីកាស្វា) ស្តីពីភូមិសុវត្ថិភាព និងកម្មវិធីឧក្រិដ្ឋកម្មនិងការការពារគ្រឿងញៀននៅខណ្ឌចំការ មន រាជធានីភ្នំពេញ នាថ្ងៃទី ៣០-៣១ ខែមីនា ឆ្នាំ ២០១០ ។<br>- មន្ត្រីគ្រួសារធម៌នៃអង្គការមិត្តសំឡាញ់បានរៀបចំកិច្ចប្រជុំ ក្រោមការគាំទ្រពីអង្គការមូលនិធិកុមារសហប្រជាជាតិ (UNICEF) ស្តីពីបណ្តាញគ្រួសារធម៌ជាមួយអង្គការដៃគូផ្សេងៗ ដើម្បីធ្វើឱ្យនីតិវិធី នៃគ្រួសារធម៌មានលក្ខណៈស្តង់ដារថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១០ និង ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១០ នៅប្រៀនឡអ៊ិនធីណាសិនណល ។<br>- អ្នកឯកទេសផ្នែកសុខភាព បានចូលរួមកិច្ចប្រជុំប្រចាំខែយ៉ាងទៀងទាត់រៀងរាល់ខែជាមួយមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ដើម្បីចែករំលែកពត៌មាន ពាក់ព័ន្ធទៅនឹងសុខភាព និងសកម្មភាព |

| | | |
|---|---|---|
| | | ដទៃទៀតជាមួយអង្គការដទៃទៀត ។<br>- អ្នកសម្របសម្រួលគឿងញៀនត្រូវបានចូលរួមធ្វើបទបង្ហាញ ស្តីពីចំណេះដឹងគ្រឿងញៀនដល់និស្សិតវិទ្យាស្ថានបច្ចេកវិទ្យាដល់និស្សិតចំនួន ៣00 នាក់ នាថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១០ ។<br>- បានបណ្តុះបណ្តាលបុគ្គលិករដ្ឋាភិបាលចំនួន ៤៤ នាក់( ស្រី ២៩នាក់) ចំនួន ៣វគ្គ មកពី១៧ សង្កាត់ ក្នុង ៥ ខណ្ឌរាជធានីភ្នំពេញ ស្តីពីសុខភាពបន្តពូជ កាមរោគ និងមេរោគអេដស៏/ជម្ងឺអេដស៏នាថ្ងៃ នា ខែកក្កដា និង ខែធ្នូ ឆ្នាំ ២០១០ ។<br>- មន្ត្រីប៉ូលីសចំនួន ២៥៥ នាក់ មកពី ៣៨ ភូមិ ៩ សង្កាត់ បានធ្វើការ និងមានកិច្ចសហការយ៉ាងជិតសិទ្ធិជាមួយក្រុមការងាររបស់បុគ្គលិកមិត្តសំឡាញ់ បន្ទប់ពីពួកគាត់បានយល់ពីគម្រោងសកម្មភាពរបស់អង្គការមិត្តសំឡាញ់ ។<br>- បុគ្គលិកចំនួន ៤នាក់ មកពីអង្គការសេវាសង្គមកិច្ចកម្ពុជា (SSC) បានទទួលការចែករំលែកបទពិសោធន៏គ្រឿងញៀន ទៅលើរបៀបធ្វើការឱ្យកាន់តែមានប្រសិទ្ធិភាពជាមួយអ្នកប្រើប្រាស់គ្រឿងញៀនរួមបញ្ចូលកម្មវិធីម្ជុល/សឺរ៉ាំងពីក្រុមការងារតាមផ្លូវរបស់អង្គកាមិត្តសំឡាញ់ នាថ្ងៃទី ៣0 ខែមិថុនា ឆ្នាំ២០១០ ។<br>- បុគ្គលិកចំនួន ២ នាក់មកពីសមាគមន៏អភិវឌ្ឍន៏ស្ត្រីកម្ពុជា បានទទួលការចែករំលែកបទ ពិសោធន៏ទៅលើកការធ្វើការជាមួយអ្នកប្រើប្រាស់គ្រឿងញៀន ជាពិសេសអ្នកប្រើប្រាស់គ្រឿងញៀន ដោយចាក់តាមសរសៃ ពីក្រុមគ្រឿងញៀនតាមផ្លូវនៃអង្គការមិត្តសំឡាញ់នាថ្ងៃទី១ខែកក្កដាឆ្នាំ ២០១០ ។<br>- អ្នកគ្រប់គ្រងមណ្ឌលស្នាក់នៅបណ្តោះអាសន្នបានសហការជាមួយខណ្ឌចំការមន ដើម្បីសុំតាំងទីមណ្ឌលស្នាក់នៅបណ្តោះអាសន្នទី១ នៅក្នុងសហគមន៏របស់គាត់នាថ្ងៃទី ២៧ ខែ សីហាឆ្នាំ ២០១០ ។<br>- បានទទួលបុគ្គលិកសង្កាត់ចំនួន ២ នាក់( ស្រី ១នាក់) នៅសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ និង |

| | | |
|---|---|---|
| | | សង្កាត់គោករកា ខណ្ឌដង្កោរបានមកធ្វើការយ៉ាងជិតស្និតជាមួយគម្រោងតាមផ្ទល់ ទាំងនៅក្នុងមណ្ឌល និងសហគមន៍។<br>- មន្ត្រីគ្រួសារធម៌បានរៀបចំកិច្ចប្រជុំបណ្ដាញគ្រួសារធម៌ចំនួន ៤ ដងស្តីពីសំភារៈអប់រំអនាម័យ ដោយមានការចូលរួមពីមន្ត្រីមកពីក្រសួងសង្គមកិច្ច និងអង្គការដៃគូចំនួន ៧រួមមាន ៖ អង្គការអភិវឌ្ឍន៍សង្គ្រោះសកលកម្ពុជា ហ្វ្រេន្ទអ៊ិនធីណាសិនណល ម៉ារីណុល កុមារីរីករាយ អង្គការទ្រទ្រង់ និងអភិវឌ្ឍន៍សុខភាពអ្នកក្រីក្រ អង្គការ ទស្សនៈពិភពលោក និងអង្គការហាការ។<br>- ប្រធានក្រុមសមាហរកម្ម និងអ្នកបណ្ដុះបណ្ដាលហ្វ្រេន្ទអ៊ិនធីណាសិនណលបានផ្ដល់ការបណ្ដុះបណ្ដាលស្ដីពីការធ្វើ សមាហរកម្ម និងរបៀបធ្វើការជាមួយគ្រួសារដល់បុគ្គលិក១០នាក់ មកពីអង្គការដែលធ្វើការ ជាមួយកុមារ នាថ្ងៃទី ៨-៩ ខែមិថុនា ឆ្នាំ២០១០ រួមមាន៖ អង្គការផ្ទះរបស់យើងអង្គការកុមារ កំព្រាក្នុងក្ដីសង្ឃឹម អង្គការខ្មែរអភិវឌ្ឍន៍សេរីភាព អង្គការគ្រួសារថ្មី អង្គការអភិវឌ្ឍន៍កុមារ និងសហគមន៍ក្រីក្រ មជ្ឈមណ្ឌលថែទាំសុខភាពកុមារ អង្គការមូលនិធិសេចក្ដីស្រលាញ់ដល់កុមារសមាគមក្ដីសង្ឃឹមកម្ពុជា អង្គការកុមារគេហរង្សី និងអង្គការម៉ារីណុល។<br>- បុគ្គលិកសង្គមបានចូលរួមកិច្ចប្រជុំស្ដីពីការអភិវឌ្ឍន៍របស់អង្គការដៃគូផ្សេងៗ ពាក់ព័ន្ធសេវានៅមន្ទីរ ពេទ្យ ខ្មែរ- សូវៀត នៅមន្ទីរពេទ្យខ្មែរ-សូវៀត នាថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១០។<br>- អ្នកសម្របសម្រួលមេរោគអេដស៍/ជម្ងឺអេដស៍ បានចូលរួមកិច្ចប្រជុំរបស់ជំនួយរបស់វិហារដាណើម៉ាក(DCA)លើការត្រួតពិនិត្យគម្រោង និងទស្សនកិច្ចគម្រោងរបស់អង្គការ លូថេរ៉ានបំរើពិភពលោក នៅខេត្តកំពង់ឆ្នាំង នាថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១០។<br>- បុគ្គលិកតាមផ្ទល់បានចូលរួមកិច្ចប្រជុំជាមួយអង្គការ HACC ស្ដីពីបញ្ហាគ្រួសាររស់នៅជាមួយមេរោគអេដស៍/ជម្ងឺអេដស៍ នៅមន្ទីរពេទ្យខ្មែរ-សូវៀត នាថ្ងៃទី ២០ខែកញ្ញា ឆ្នាំ២០១០។ |

| | | |
|---|---|---|
| | | - អ្នកគ្រប់គ្រងគំរោងវប្បធមិបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរក្នុងស្រុក និងអង្គការនីញ៉ូម៉ូកម្ពុជា មជ្ឈមណ្ឌលវប្បធមិបារាំង ព្រះបរមរាជវាំង សារមន្ទីជាតិ និងសារមន្ទីរគុកទួលស្លែង ដើម្បីរៀបចំទស្សនកិច្ចសិក្សា និងព្រឹត្តិការណ៍ពិសេសផ្សេងៗ។<br>- បុគ្គលិកស្ម័គ្រចិត្តនៃធនាគារ ANZ ចំនួន ២៩នាក់(ស្រី១៩នាក់) ចូលរួមសកម្មភាពជាមួយកុមារ រួមមានៈ ការគូរគំនូរ និទានរឿង វាយសី ធ្វើផ្កាក្រដាស និង លេងបាល់ទាត់។<br>- អង្គការនីញ៉ូម៉ូកម្ពុជាបានបញ្ជូនកុមារអោយចូលរួមសកម្មភាពវប្បធមិរួមមានៈ កីឡា ការរាំ គូរគំនូរ និងអានសៀវភៅ ២ដង/១ខែ។<br>- ប្រធានក្រុមខេត្តកំពង់ចាមបានសហការជាមួយមេភូមិទាំង ៦ នៅក្នុងសង្កាត់វាលវង់ ដើម្បីផ្សព្វផ្សាយស្តីពីចំណាកស្រុកមានសុវត្ថិភាព បំណិនជីវិត និងថែមទាំងបានទំនាក់ទំនងជាមួយមេឃុំ សង្គមកិច្ចស្រុកដើម្បីស្វែងរកគ្រួសារ នៅក្នុងស្រុកមេមត់ ស្ទឹងត្រង់ ចំការលើ កំពង់ចាម កំពង់សៀម ព្រៃឈរ បាធាយ កោះសូទិន និងបានទំនាក់ទំនងជាមួយមន្ទីរសង្គមកិច្ចខេត្ត ដើម្បីធ្វើការប្រជុំជាមួយម្ចាស់ជំនួយសហភាពអឺរ៉ុប និងបានចូលរួមសិក្ខាសាលារបស់មន្ទីរសង្គមកិច្ចខេត្តកំពង់ចាមក្រោមប្រធានបទនីតិវិធីនៃការអនុវត្តរវាងកម្ពុជា និងវៀតណាមក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយសារការជួញដូរ ។<br>- ប្រធានគម្រោងកំពង់ចាមបានទំនាក់ទំនង និងជួបប្រជុំជាមួយចៅសង្កាត់កំពង់ចាម និងអភិបាលក្រុង ស្តីពីការរុះរើផ្ទះរបស់គ្រួសារ និងការរៀបចំប្លង់ដីសំរាប់ប្រជាពលរដ្ឋនៅសហគមន៍វាលខ្សាច់ និង សំបុកចាប។<br>- ប្រធានគម្រោងខេត្តកំពង់ចាមបានចូលរួមប្រជុំជាមួយក្រុមសមាហរកម្ម ស្តីពីការដោះស្រាយករណីរបស់កុមារជាមួយមន្ទីរសង្គមកិច្ច និងបានទំនាក់ទំនងជាមួយមេភូមិដើម្បីធ្វើការផ្សះផ្សារ |

| | | |
|---|---|---|
| | | គ្រួសារនៅភូមិឡូតដ្ឋដែលប្រើអំពើហិង្សាគ្រួសារ។<br>- ប្រធានគំរោងកំពង់ចាមបានជូនដំណឹងដល់ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈអំពីក្រុមហ៊ុនចុះផ្សព្វផ្សាយ ជ្រើសរើសប្រជាពលរដ្ឋទៅធ្វើការនៅប្រទេសម៉ាឡេស៊ីខុសច្បាប់។ |
| ១.៥.សម្របសម្រួលជាមួយនឹងដៃគូ FAនិង CYTI ផ្សេងទៀត។ | -ការផ្លាស់ប្តូរបទពិសោធន៍ និងសហការជាមួយនឹង អង្គការកល្យាណមិត្ត (Kaliyan Mith) និងកម្មវិធី FA ផ្សេងទៀតប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព។<br><br>- ប្រព័ន្ធសម្របសម្រួល និង បញ្ជូនមានដំណើរការជាមួយនឹងសមាជិកបណ្តាញCYTIក្នុងប្រទេសកម្ពុជា និងអន្តរជាតិ។ | - ប្រធានគម្រោងអប់រំ និងប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបានទស្សនកិច្ចគម្រោងកល្យានមិត្តនៅខេត្តសៀមរាប ដើម្បីទទួលបទពិសោធន៍ លើការបណ្តុះបណ្តាលវិជ្ជាជីវៈ និងមណ្ឌលសំចត ។ តាមរយៈការទស្សនកិច្ចនេះ យើងអាចកែសំរួលកម្មវិធីសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលដើម្បីពង្រឹងគុណភាពនៃការ បង្រៀន និងសេវាខាងក្រៅ នាថ្ងៃទី ៨-៩ ខែ មេសា ឆ្នាំ២០១០។<br>- បុគ្គលិកកល្យានមិត្តសៀមរាបចំនួន ៣ នាក់ បានមកទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធសកម្មភាពធ្វើការជាមួយកុមារតាមផ្លូវ ទាំងនៅតាមផ្លូវ និងមណ្ឌល នៅអង្គការមិត្តសំឡាញ់ រាជធានីភ្នំពេញ នាខែសីហា និងខែធ្នូ ឆ្នាំ ២០១០។<br>- បុគ្គលិកហ្វ្រេន្ឋអ៊ិនធីណាសិនណាលថៃ(ភឿនភឿន)ចំនួន៥នាក់(ស្រី១នាក់)បានមកទស្សនកិច្ច និងចែករំលែកបទពិសោធន៍ជាមួយគំរោងតាមផ្លូវ នាថ្ងៃទី ១១-១៥ ខែមករា ឆ្នាំ ២០១០។<br>- បុគ្គលិកក្រុមសិប្បកម្មតាមផ្ទះនៃអង្គការមិត្តសំឡាញ់ និងហ្វ្រេន្ឋអ៊ិនធីណាសិនណល បានទស្សនកិច្ចសិក្សាគម្រោង របស់ហ្វ្រេន្ឋអ៊ិន ធើណាសិនណល នៅទីក្រុងបាងកក ប្រទេសថៃ និងដើម្បីរុករកនូវគំនិតថ្មីៗ និងទិញសំភារៈ វត្ថុធាតុដើមខ្នាតធំ។<br>- ដោយមានកិច្ចសហកាល្អជាមួយសមាជិកបណ្តាញ CYTI អង្គការមិត្តសំឡាញ់បានធ្វើបទបង្ហាញកម្មវិធីរបស់ខ្លួនរួមមានៈ អប់រំក្រៅប្រពន្ធ័ សកម្មភាពនៃការផលិតសៀវភៅ ឧបករណ៍សិក្សា និងសកម្មភាពតាមផ្លូវ ដល់សមាជិកបណ្តាញចំនួន ៦ នាក់(ស្រី១នាក់) មកពីអេហ្សីប និងថៃមទាំង |

| | | |
|---|---|---|
| | | ទស្សនកិច្ចមណ្ឌលស្នាក់នៅបណ្ដោះអាសន្នទី១ នាថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០១០។<br>- អង្គការមិត្តសំឡាញ់បានរៀបចំកិច្ចប្រជុំបណ្ដាញអ្នកធ្វើការងារជាមួយកុមារតាមផ្លូវនៅកម្ពុជាចំនួន ៣ ដង នៅហ្វ្រេន្ឌអ៊ិនធើណាសិនណលស្ដីពី លទ្ធផលកម្រងឯកសារកុមារតាមផ្លូវ ២០០៨ ការកែលំអរ/អនុសាសន៍សំរាប់កម្រងឯកសារកុមារតាមផ្លូវឆ្នាំថ្មី បទបង្ហាញពីសំភារៈអប់រំតាមផ្លូវ និងបានធ្វើការអង្កេតផតព្រៀងទុកប្រចាំឆ្នាំ។<br>- បានចូលរួមការប្រជុំប្រចាំត្រីមាសយ៉ាងទៀងទាត់ ជាមួយគម្រោងប្រតិបត្តិល្អរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីបន្តការចែករំលែកបទពិសោធន៍ជាមួយសមាជិកដទៃទៀត។ |
| ***លទ្ធផលទី២:នៅឆ្នាំ ២០១១ ដៃគូបណ្ដាញការពារ សុវត្ថិ ភាពកុមារ (ChildSafe Network) ចំនួន ៧០០ នឹងការពារគាំទ្រដល់កុមារចំនួន ៥.០០០ នាក់ នៅក្នុងទីក្រុងភ្នំពេញនិងខេត្តកំពង់ចាម។*** | | |
| ២.១ កំណត់ និងបណ្ដុះបណ្ដាលសមាជិកការពារសុវត្ថិភាពកុមារ(ChildSafe) ចំនួន៦០០ នាក់។ | - សមាជិកការពារសុវត្ថិភាពកុមារ (ChildSafe)ចំនួន៦០០នាក់ ទទួលបានការបណ្ដុះបណ្ដាលនិងវិញ្ញាប័នបត្រ នៅឆ្នាំ ២០១១។ | • នៅឆ្នាំនេះ មានសមាជិកការពារសុវត្ថិភាពកុមារសរុប ៤៦៧នាក់ រួមបញ្ចូលសមាជិកថ្មី ៩៦នាក់ ទទួលបានការបណ្ដុះបណ្ដាល និងវិញ្ញាបនបត្រ។<br>**- សមាជិកភ្នំពេញ ៣៤៤នាក់** (ថ្មី ៧១នាក់)<br>(ម៉ូតូឌុបៈ១៧៣ (ថ្មី៣៦នាក់), ម៉ូតូរ៉ឺម៉កៈ១៦៧(ថ្មី៣៥នាក់),តាក់ស៊ីៈ ០៤។<br>**- សមាជិកកំពង់ចាម ១២៣នាក់** (ថ្មី ២៥នាក់)<br>(ម៉ូតូឌុបៈ ១០២(ថ្មី២៣នាក់), ម៉ូតូរ៉ឺម៉កៈ ២១នាក់ (ថ្មី ០២ នាក់)<br>ក្នុងឆ្នាំនេះ សមាជិកសុវត្ថិភាពចំនួន ១១០នាក់ បានលុបឈ្មោះចេញពីបញ្ជីសមាជិកសុវត្ថិភាពកុមារ នៅភ្នំពេញ និងកំពង់ចាម ដោយសារតែៈ ផ្លាស់ប្ដូរមុខរបរ និងត្រឡប់ទៅស្រុកកំណើត។ |

| | | |
|---|---|---|
| | - សមាជិកទាំងអស់ នឹងទទួលបានការបណ្តុះបណ្តាលឡើងវិញជារៀងរាល់ឆ្នាំ។<br><br>-សមាជិកទាំងអស់ត្រូវបានវាយតម្លៃ និងតាមដានជាបន្តបន្ទាប់។ | - ៦០នាក់ ជាអ្នករត់ម៉ូតូឌុប នៅភ្នំពេញ<br>- ៤៨ នាក់ ជាអ្នករត់ម៉ូតូរ៉ឺម៉ក នៅភ្នំពេញ<br>- ២ នាក់ ជាអ្នករត់ម៉ូតូឌុប នៅកំពង់ចាម<br>• សមាជិកសុវត្ថិភាពកុមារទាំងអស់ ទទួលបានការបណ្តុះបណ្តាល និងរំលឹកមេរៀនឡើងវិញលើប្រធានបទដូចជាៈ សុវត្ថិភាពកុមារ ចំណាកស្រុកមានសុវត្ថិភាព ផ្លូវសុវត្ថិភាព ផលលំបាកនៃការផឹកគ្រឿងស្រវឹង លេងល្បែង និងបានផ្តល់ពត៌មានស្តីពីគ្រឿងញៀន បំណិនជីវិត និងសង្គ្រោះបឋម។<br>• សមាជិកសុវត្ថិភាពកុមារ ៤៦៧នាក់ ត្រូវបានតាមដាននិងវាយតម្លៃជាបន្តបន្ទាប់ក្នុងឆ្នាំនេះ។ |
| ២.២ កំណត់ និងបណ្តុះបណ្តាល ដៃគូការពារសុវត្ថិភាពកុមារ(ChildSafe) ចំនួន១០០នាក់ | -ដៃគូការពារសុវត្ថិភាពកុមារ(ChildSafe) ចំនួន ១០០ នាក់ ទទួលបានការបណ្តុះបណ្តាលនិងវិញ្ញាបន័បត្រនៅឆ្នាំ ២០១១។<br>-ដៃគូទាំងអស់ទទួលបានការបណ្តុះបណ្តាលឡើង វិញជារៀងរាល់ឆ្នាំ។<br>-ដៃគូទាំងអស់ត្រូវបានវាយតម្លៃ និងតាមដានជាបន្តបន្ទាប់។ | • បុគ្គលិកធនាគារ ANZ Bank Royal ចំនួន ១៩៦នាក់ (ថ្មី ៣៣នាក់)ដែលជាដៃគូការពារសុវត្ថិភាពកុមារទទួលបានការបណ្តុះបណ្តាល និងវិញ្ញាបនបត្រ។ |
| ២.៣ គាំទ្រដល់សមាជិក និងដៃគូការពារសុវត្ថិភាពកុមារ (ChildSafe) ដើម្បីផ្តល់ការការពារដល់កុមារចំនួន | - កុមារចំនួន ១.០០០នាក់ ទទួលបានការបញ្ជូននៅ ឆ្នាំ ២០១១។<br>- កុមារចំនួន ៥.០០០ នាក់ ទទួលបានការការពារនៅឆ្នាំ ២០១១។ | - កុមារចំនួន ៤៤០នាក់(ស្រី១៧៥នាក់) បានបញ្ជូនទាំងនៅភ្នំពេញ និងកំពង់ចាម។<br><br>- កុមារចំនួន ២,៧៩៥នាក់ (ស្រី ៩៥៦ នាក់) ទទួលបានការគាំទ្រ និងការពារដោយផ្តល់ពត៌មានដល់ពួកគេតាមរយៈទូរស័ព្ទ Hotline មណ្ឌលសុវត្ថិភាពកុមារភ្នំពេញ និងសុវត្ថិភាពកុមារ |

| | | |
|---|---|---|
| ៥.000 នាក់ ។ | - មណ្ឌលការពារសុវត្ថិភាព កុមារ (ChildSafe) នៅ ក្នុងទីក្រុងភ្នំពេញ ត្រូវបានប្រតិបត្តិដោយអង្គការមិត្ត សំឡាញ់ នៅឆ្នាំ២០១១ ។ | កំពង់ចាម ។<br>• កន្លងមកក្រុមការងាររបស់មិត្តសំឡាញ់ បានទំនាក់ទំនងជាមួយមណ្ឌលសុវត្ថិភាពកុមារនៃអង្គការហ្វ្រេនអ៊ិនធីណាសិនណលលើការងារជាច្រើនដូចជា:<br>- សង្គ្រោះកុមារតាមរយៈទូរសព្ទ័សុវត្ថិភាពកុមារ និងផ្តល់ពតិមានត្រឡប់ទៅមណ្ឌលការពារសុវត្ថិភាពកុមារគ្រប់ករណើរបស់កុមារ ។<br>- ក្រុមការងារសុវត្ថិភាពកុមារបានផ្សព្វផ្សាយខិតប័ណ្ណណែនាំ ៧ចំណុច នៅតាមសណ្ឋាគារដែលជាសមាជិកសុវត្ថិភាពកុមារ ។<br>- សមាជិកសុវត្ថិភាពកុមារទាំងអស់ បានទំនាក់ទំនងញឹកញាប់ជាមួយមណ្ឌលសុវត្ថិភាពកុមារតាមរយៈការជួយកុមាររងគ្រោះនិងបាននាំភ្ញៀវទេសចរណ៏មកទស្សនាមណ្ឌលទៀតផង ។ |
| ២.៤ ចូលរួមផ្សព្វផ្សាយយុទ្ធនាការអន្តរជាតិ ស្តីពីការពារសុវត្ថិភាពកុមារនៅក្នុងទីក្រុងភ្នំពេញ(សម្រាប់អ្នកទេសចរ)ដែលផ្តោតគោលដៅចំពោះអ្នកទេសចរណ៏អន្តរជាតិចំនួន៣០%ដែលមកកាន់ទីក្រុងភ្នំពេញក្នុងមួយឆ្នាំ។ ។ | - យុទ្ធនាការអន្តរជាតិស្តីពី បញ្ឈប់ការអោយលុយទៅកុមារតាមថ្នល់ ត្រូវបានសម្ពោធ និងអនុវត្តនៅក្នុងទីក្រុងភ្នំពេញនៅដើមត្រីមាសទី២ នៃ ឆ្នាំ ២០០៨ ។<br>-យុទ្ធនាការផ្សព្វផ្សាយដល់អ្នកទេសចរណ៏ត្រូវបានអនុវត្តនៅក្នុងទីក្រុងភ្នំពេញនៅត្រីមាសទី៤នៃឆ្នាំ២០០៨ ។<br>-អ្នកទេសចរមកទីក្រុងភ្នំពេញចំនួន៣០%ក្នុងមួយឆ្នាំទទួលបានការអប់រំផ្សព្វផ្សាយ | • យុទ្ធនាការបានធ្វើតាំងពីឆ្នាំ២០០៨ ។<br>• ខិតបណ្ណ័ណែនាំ ៧ចំណុច សំរាប់អ្នកធ្វើដំណើរបានចាប់ផ្តើប្រើប្រាស់តាំងពីឆ្នាំ២០០៨ ហើយឥឡូវនេះយើងបានបកប្រែជាភាសា ៣ ភាសារួមភាសាបារាំង ជប៉ុន និងចិន ។ |

| លទ្ធផលទី៣: នៅឆ្នាំ ២០១១ គម្រោងមាននិរន្តភាព ៦០% តាមរយៈការបង្កើតកម្មវិធីអាជីវកម្មតាមរយៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងអាជីវកម្មសង្គម ។ | | |
|---|---|---|
| ៣.១ ការបង្កើតការបណ្តុះបណ្តាលអាជីវកម្ម | - ភោជនីយដ្ឋានចំនួន ៣ មាន ដំណើរការ<br>- ការបណ្តុះបណ្តាលវិជ្ជាជីវៈទាំងអស់មានមុខងារជាអាជីវកម្មនៅឆ្នាំ ២០១១។ | ថ្នាក់ចុងភៅចំនួន ៣ កំពុងដំណើរការធ្វើជំនួញនាពេលបច្ចុប្បន្ននេះ រួមមាន: ឡឺ ការហ្វេមិត្តសំឡាញ់ ថ្នាក់ចុងភៅកំរិត២ (រំដេង) និងថ្នាក់ចុងភៅកំរិត៣ (ហ្វ្រេន្ឌ្ស) ។<br>• **ឡឺ ការហ្វេមិត្តសំឡាញ់** ស្ថិតនៅក្នុងសួនច្បារដ៏ឆើតឆាយនៃមជ្ឈមណ្ឌលវប្បធម៌បារាំង ជាថ្នាក់បណ្តុះបណ្តាល មានបំរើសេវាកម្មអាហារពេលព្រឹក អាហារថ្ងៃត្រង់ប៊ូហ្វេខ្មែរ និងទទួលរៀបចំសំរាប់ព្រឹត្តិការណ៏ផ្សេងៗ នាពេលល្ងាច។ ភោជនីដ្ឋានបណ្តុះបណ្តាលនេះ ស្វាគមន៍សំរាប់សិស្សកំរិតមួយ លើសេវាចំអិន ដើម្បីទទួលបានបទពិសោធន៍ជាអាជីពជាមូលដ្ឋាន និងការទំនាក់ទំនងជាមួយ អតិថិជន លើសេវាអាហារប្រភេទប៊ូហ្វេ ។<br><br>• **ថ្នាក់ចុងភៅរំដេង** គឺជាថ្នាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្នែកចុងភៅកំរិត២ មានបំរើជាលក្ខណៈម្ហូបបែបខ្មែរ មានអាហារពិសេសប្រចាំសប្តាហ៏និងមានជាអាហារឈុតសំរាប់ផ្តល់ជូនអតិថិជនជារៀងរាល់ថ្ងៃ។ ជាមធ្យមក្នុងមួយខែ ភោជនីយដ្ឋានរំដេងមានសិស្សចំនួន ៣០នាក់ បានទទួលវគ្គបណ្តុះបណ្តាល ហើយក្នុងនោះក៏មានសិស្សចំនួន ០៩នាក់ ដែលចេញទៅធ្វើការងារបានដោយខ្លួនឯង។ នៅក្នុងឆ្នាំនេះសិស្សសរុប ៦៤នាក់(ស្រី១៣នាក់)បានទទួលវគ្គបណ្តុះបណ្តាលផ្នែកខាងសេវាកម្ម និងការចំអិនម្ហូបនៃគម្រោងរបស់មិត្តសំឡាញ់។ សិស្សសរុបចំនួន១៥នាក់បានបញ្ចប់នៅថ្នាក់ចុងភៅរំដេង ហើយកំពុងបន្តរៀននៅថ្នាក់ចុងភៅហ្វ្រេន្ឌ្ស។<br>• **ថ្នាក់ចុងភៅហ្វ្រេន្ឌ្ស** គឺជាថ្នាក់ចុងភៅកំរិត៣ មានបំរើនូវម្ហូបបែបអាស៊ីនិងអឺរ៉ុបជាលក្ខណៈ ចានតូច ហើយក៏មានម្ហូបពិសេសប្រចាំ សប្តាហ៏បែបចានធំផងដែរ ដោយមានការផ្លាស់ប្តូរ និងបង្ហាញពីរបៀបផ្តល់សេវាកម្មជូនអតិថិជន និងវិធីសាស្រ្តនៃការបង្រៀនសិស្សផងដែរ។ ជាមធ្យម ភោជនីយ |

| | | |
|---|---|---|
| | - អាជីវកម្មតាមរយៈ ផ្តល់ការបណ្តុះបណ្តាលទាំង អស់អាចផ្តល់ប្រាក់ចំណេញបន្ទាប់ពីដំណើរ ការបាន ១៨ ខែ ។<br>- ចូលរួមផ្តល់ថវិកា ៦០% នៃផលចំណេញសរុប ។ | ដ្ឋានហ្វ្រេន្ទផ្តល់វគ្គបណ្តុះបណ្តាលដល់សិស្សចំនួន ២៨នាក់។ សិស្សសរុប ៤៦នាក់ (ស្រី៩នាក់) បានទទួលវគ្គបណ្តុះបណ្តាលផ្នែកខាងសេវាកម្ម និងការចំអិនម្ហូបនៃគំរោងរបស់មិត្តសំឡាញ់ ។<br>• ការធ្វើក្រចក(ថ្នាក់សំអាង) គឺជាថ្នាក់បណ្តុះបណ្តាលអាជីវកម្មស្ថិតនៅក្នុងហាងហ្វ្រេន្ទអេន ស្តាហ្វ ជិតភោជនីយដ្ឋានហ្វ្រេន្ទ។ សិស្សទាំងនោះ មកពីថ្នាក់សំអាងនៃអង្គការមិត្តសំឡាញ់ដែលផ្តល់ឱកាសឱ្យធ្វើការក្នុងកំឡុងពេលសិក្សា និងទទួលបានបទពិសោធន៍បន្ថែម ខណៈពេលរង់ចាំការធ្វើសមាហរកម្ម។<br>ក្រៅពីនេះក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មានមុខវិជ្ជាផ្សេងៗទៀតក៏បានរកប្រាក់ចំណូលផងដែររួមមានៈ កាត់ដេរ ជួសជុលម៉ូតូ ជួសជុលឡាន អគ្គិសនី អេឡិចត្រូនិច បោកគក់ ផ្សារដែក កសិកម្ម ចុងភៅកិរិត១ កាត់សក់ និងថ្នាក់សំអាង ។<br>• អាជីវកម្មតាមរយៈការបណ្តុះបណ្តាលទាំងអស់ អាចទទួលបានប្រាក់ចំណូល ៨៧៩,៤៣១.១០ ដុល្លា និងចំណេញ ១៩៥,៥០៧.៤០ ដុល្លាបានមកពីថ្នាក់ចុងភៅរដេង ហ្វ្រេន្ទ និងថ្នាក់ធ្វើ ក្រចក និងថ្នាក់បណ្តុះបណ្តាលទាំងអស់។<br>• ចូលរួមផ្តល់ថវិកា ៣៣% នៃប្រាក់ចំណូលសរុប។ |
| ៣.២ ការបង្កើតអាជីវកម្មផ្នែកសង្គមកិច្ច | -ការស្រាវជ្រាវទីផ្សារត្រូវបានអនុវត្ត នៅឆ្នាំ ២០០៩ | • ការស្រាវជ្រាវទីផ្សារអាជីវកម្មខ្នាតតូច ត្រូវបានធ្វើឡើងដោយជំនួយការបច្ចេកទេស និងអ្នកគ្រប់គ្រងអាជីកម្មក្នុងស្រុក នាខែមករា-មិនា ២០១០ ជាមួយអ្នកប្រកបអាជីវកម្មខ្នាតតូចចំនួន ៣៣ នាក់ នៅក្នុងសហគមន៍ច្បារអំពៅ បូរីកីឡា សាមគ្គី បឹងកក់ ផ្សារតូច និងអណ្តូង រួមបញ្ចូល ផ្សារអូឬស្សី ផ្សារទួលគោក ផ្សារច្បារអំពៅ បូរីកីឡា និងនៅជិតសាលាខ្លះក្នុងមជ្ឈមណ្ឌល រាជធានីភ្នំពេញ ជុំវិញផ្លូវ |

| | | |
|---|---|---|
| | | ១៩, ១៥ និងផ្លូវ២១៤ ។ ជាលទ្ធផល កម្មវិធីសិក្សាអាជីវកម្មខ្នាតតូច ត្រូវបានបង្កើតឡើងសំរាប់បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់ក្រុមគោលដៅដើម្បីចាប់ផ្តើមអាជីកម្មប្រកបដោយនិរន្តភាព។ |
| | -អាជីវកម្មសង្គមចំនួន ២ ត្រូវបានបង្កើតឡើងនៅ ឆ្នាំ ២០១១។ | • អាជីវកម្មសង្គម១ ត្រូវបានបង្កើតឡើងគឺ សិប្បកម្មតាមផ្ទះ (ភ្នំពេញ និងកំពង់ចាម)។<br>- គំរោងនៅតែដំណើរការជាមួយអ្នកចូលរួមចំនួន ១០៧នាក់ នៅសហគមន៍អណ្តូង នៅភ្នំពេញ ហើយអ្នកចូលរួមខ្លះបានបោះបង់ចោល និងខ្លះទៀតបានផ្អាក។<br>- បុគ្គលិកផ្នែកផលិតត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងផ្នែកផលិតនៅសហគមន៍អណ្តូង។ អ្នកចូលរួមទទួលបានថវិកាជាមធ្យម ៨៧ ដុល្លារ/១ខែ នៅភ្នំពេញ និង៩៧ដុល្លា/១ខែ នៅសហគមន៍អណ្តូង ។<br>- ពាក់កណ្តាលនៃគ្រួសារសិប្បកម្មតាមផ្ទះ បានមកផលិតផលិតផលនៅប្រេនអ៊ិនធឺណាសិនណលសំរាប់ការបញ្ជាទិញពិសេស ជាលទ្ធផលពួកគាត់ទទួលបានប្រាក់ចំណូលនិង ជំនាញបន្ថែម។<br>- កម្មវិធីបណ្តុះបណ្តាលជំនាញសិប្បកម្មតាមផ្ទះកំពុងពង្រាង ហើយនឹងបញ្ចប់នៅឆ្នាំក្រោយ។<br>- ក្រុមការងារបានរៀបចំដំណើរកំសាន្តទៅក្រុងព្រះសីហនុដល់គ្រួសារ សហគមន៍ អណ្តូង និងក្រុមសិប្បកម្មតាមផ្ទះ រាជធានីភ្នំពេញ ដើម្បីបង្កើតសាមគ្គីភាព និងលើកទឹកចិត្តដល់ ពួកគាត់។<br>- ក្រុមសិប្បកម្មតាមផ្ទះបានចូលរួមព្រឹត្តិការណ៍ ពិព័ណ៌បៃតង់នៅសាលាអន្តរជាតិភ្នំពេញ ពិធីបុណ្យណូអែលរបស់ក្រុមហ៊ុន ប៊ីឡាញ និងពិព័ណ៌ Fun Fair ដើម្បីផ្សព្វផ្សាយពីផលិតផលរបស់ខ្លួន។<br>- ផ្នែកបោះពុម្ភកំពុងដំណើរការចាប់តាំងពី ឆ្នាំ២០១០ និងទទួលការបញ្ជាទិញជាច្រើនពីខាងក្នុង និង ខាងក្រៅ ។ |

| | | |
|---|---|---|
| | -អាជីវកម្មផ្នែកសង្គមកិច្ច ទាំងអស់ផ្តល់ប្រាក់ ចំណេញបន្ទាប់ពីដំណើរការបាន១២ខែ ។<br>- ចូលរួមវិភាគទាន ៣០% នៃប្រាក់ចំណេញសរុប ។ | - គំរូថ្មីជាច្រើនត្រូវបានបង្កើតដើម្បីឆ្លើយតបទៅនឹងតំរូវការទីផ្សារ ។<br>- ផលិតផល ៣២ មុខត្រូវបានបង្កើត និងផលិតសំរាប់ការលក់នៅក្នុង និងក្រៅស្រុក ។ អតិថិជនក្រៅស្រុករួមមានៈ អ៊ឺរ៉ុប អូស្ត្រាលី សាំងហ្គាពួរ កាន់ណាដា និងអាមេរិច តាមរយៈប្រ៊្រេនឡ្យ អ៊ិនធឺណាសិនណល ។<br>- សិស្សានុសិស្ស និងលោកគ្រូមកពីសាលាបឋមសិក្សាបារាំងបានចុះទស្សកិច្ចសិក្សាលើសិក្ខាសាលានៃគម្រោងសិប្បកម្មតាមផ្ទះ ។<br>• អាជីវកម្មផ្នែកសង្គមកិច្ចទទួលបានប្រាក់ចំណូល ១០៤,៧៩៦.៣២ ដុល្លា និងប្រាក់ចំណេញ ១៨,៣៦០.៩៦ ដុល្លា ។<br>• ចូលរួមផ្តល់ថវិកា ៤% នៃប្រាក់ចំណូលសរុប ។ |
| ៣.៣ ការបង្កើតសេវាកម្ម និងផលិតផលរកប្រាក់ចំណូល | - ផលិតផលត្រូវបានរចនាម៉ូត ជាបន្តបន្ទាប់( សរុប១០មុខនៅឆ្នាំ២០១១ ។ | • **ហាងលក់ទំនិញប្រ៊្រេនឡ្យ អេន ស្ពាហ្វ** ស្ថិតនៅជិតភោជនីដ្ឋានប្រ៊្រេនឡ្យ មានលក់សៀវភៅចាស់ៗ សំលៀកបំពាក់ និងផលិតផលដែលធ្វើដោយៈ<br>- ឪពុកម្តាយក្នុងគំរោងសិប្បកម្មតាមផ្ទះនៅប្រទេសកម្ពុជានិងឡាវ<br>- យុវវ័យក្នុងថ្នាក់ជំនាញវិជ្ជាជីវៈ ព្រមទាំងសំភារៈឧបត្ថម្ភដទៃផ្សេងទៀត និងផលិតផលមកពីអង្គការដទៃ ទៀតរួមមានៈ វិចិត្រសាលគំនូរីករាយ សមាគមន៏សង្គ្រោះសត្វជីវ៉ភ្នំតាម៉ៅ ដឹរសសង្គ្រោះសត្វព្រៃនៅកម្ពុជា ស៊ីប៉ា អប់រំពិភពលោក អង្គការស្ត្រីផ្ទុកមេរោគអេដស៏ រោងចក្រថ្មែម៉ូថទំនើប |

| | | |
|---|---|---|
| | - ចូលរួមផ្តល់ថវិកា ១០% នៃប្រាក់ចំណេញសរុប ។ | - បានចុះកុងត្រាជាមួយកន្លែងផ្ញើរលក់ចំនួន១២រួមមានៈ អង្គការកម្ពុជាជួយជនរងគ្រោះដោយទឹកអាស៊ីត អង្គការស អង្គការដំណក់ទឹកប៉ោយប៉ែត អង្គការជីវិស អង្គការអូស្ទ្រូសអង្គការសង្គ្រោះសត្វព្រៃនៅកម្ពុជា ស៊ីប៉ា មួប់តាប៉ាង សមាគមន៍ចាស់ជរាខេត្តតាកែវ សង្គ្រោះសត្វជីវីភ្នំតាម៉ៅ បឹងឈូក និងវិចិត្រសាលគំនូររីករាយ ។<br>• **សៀវភៅធ្វើម្ហូប** ត្រូវបានផលិតតាំងពី ខែធ្នូ ឆ្នាំ ២០០៤ អាចរកទិញបាននៅភោជនីដ្ឋានប្រ៊្រេន្ស រំដេង ហាងលក់ទំនិញប្រ៊្រេន្ស អេន ស្តាហ្វ ហាងទូចទូច ហាង ២៤០ បណ្ណាគារ Monument Books និងនាំចេញទៅប្រទេសអង់គ្លេស និងកន្លែងផ្ញើរលក់ទាំង នៅភ្នំពេញនិងសៀមរាប សំរាប់បង្កើនប្រាក់ចំនូលដល់អង្គការ ។ ទទួលបានប្រាក់ចំណូល ៤៣,៤៤៦.៤០ដុល្លា និងចំណេញ ២៤,០៩១.៧៥ ដុល្លា ។<br>• ចូលរួមផ្តល់ថវិកា ៧ % នៃប្រាក់ចំណូលសរុប ។ |
| ***លទ្ធផលទី៤:នៅឆ្នាំ ២០១១ អង្គការមិត្តសំឡាញ់*** (Mith Samlanh) ***ត្រូវបានទទួលស្គាល់ថាជាអង្គការមាន ប្រព័ន្ធរដ្ឋបាលល្អបំផុត ។*** | | |
| ៤.១ បង្កើតការិយាល័យគណនេយ្យប្រកបទៅដោយប្រសិទ្ធភាព ទាន់ពេលវេលា និងមានដំណើរការយ៉ាងមានតម្លាភាព ពេញលេញ ។ | - SoP របស់ប្រព័ន្ធគណនេយ្យ ត្រូវបានអនុវត្តនៅ ត្រីមាសទី ៤ នៃឆ្នាំ ២០០៨ ។<br>- សវនកម្មធ្វើឡើងទាន់ពេលវេលា និងមានលក្ខណៈវិជ្ជមាន ។<br>-របាយការណ៍គណនេយ្យ ត្រូវបានផ្ញើជូនទៅគណៈគ្រប់គ្រងនិងក្រុមការងារជារៀង | • បទដ្ឋាននៃនីតិវិធីរបស់ប្រព័ន្ធគណនេយ្យកំពុងស្ថិតក្នុងដំណើរការណ៍ព្រាងនៅឡើយ ។<br>• របាយការណ៍សវនកម្មនៃអង្គការមិត្តសំឡាញ់ឆ្នាំ២០០៩ បានបញ្ចប់ ហើយសវនកម្មអង្គការមិត្តសំឡាញ់សំរាប់ឆ្នាំ ២០១០ នឹងចាប់ផ្តើម នៅឆ្នាំ ២០១១ ។<br>• របាយការណ៍គណនេយ្យមានលក្ខណៈល្អប្រសើរជាងឆ្នាំមុន ។ |

| | | |
|---|---|---|
| | រាល់ខែ។ | |
| ៤.២ កសាងផ្នែកគ្រប់គ្រងរដ្ឋបាលប្រកបដោយប្រសិទ្ធភាពក្នុងការគាំទ្រដើម្បីអោយការអនុវត្តន៍សេវាកម្មបានល្អដែល ទទួលស្គាល់ថាជាការអនុវត្តន៍ ល្អបំផុត។ | - SoPរបស់ប្រព័ន្ធរដ្ឋបាលត្រូវបានអនុវត្តនៅត្រីមាសទី៤ នៃឆ្នាំ ២០០៨<br><br>- SoP របស់ប្រព័ន្ធធនធានមនុស្សត្រូវបានអនុវត្តនៅត្រីមាសទី៤នៃឆ្នាំ ២០០៨។<br><br>- រាល់ការទំនាក់ទំនង (ខាងក្នុង និងខាងក្រៅ) ត្រូវបានដំណើរការប្រកបដោយប្រសិទ្ធិភាព។<br><br>- ការទំនាក់ទំនងជាមួយនឹង FA និង CYTI ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព។<br><br>-CCC នឹងរក្សាវិញ្ញាបនបត្រលើការប្រតិបត្តិល្អ ចំពោះអង្គការ GPP | • បទបញ្ជាផ្ទៃក្នុងរបស់អង្គការមិត្តសំឡាញ់បានបញ្ចប់ និងឯកភាពពីសមាជិកក្រុមប្រឹក្សាភិបាល ហើយក៏បានធ្វើបទបង្ហាញជូនដល់ប្រធានក្រុម អ្នកគ្រប់គ្រប់គំរោង និងគណៈគ្រប់គ្រង់ទាំងអស់នៅក្នុងឆ្នាំនេះ និងចាប់ផ្តើមអនុវត្តដើមឆ្នាំ២០១១។<br>• បទដ្ឋាននៃនីតិវិធីរបស់ប្រព័ន្ធធនធានមនុស្សត្រូវបានកែប្រែសំរាប់ការកែលំអលើការជ្រើសរើសបុគ្គលិក និងការវាយតម្លៃបុគ្គលិក។<br><br>• តាមរយៈកិច្ចសហការពីមន្ត្រីផ្នែកទំនាក់ទំនង ហ្វ្រេន្ឋអ៊ិនធីណាសិនណល អង្គការមិត្តសំឡាញ់ត្រូវបានទទួលស្គាល់ច្រើនតាមរយៈសារពតិមានសំខាន់ៗ ក៏ដូចជាការមកធ្វើទស្សនកិច្ចពីភ្ញៀវទេសចរណ៏នានា។<br><br>• ការទំនាក់ទំនងជាមួយនឹងហ្វ្រេន្ឋអ៊ិនធីណាសិនណល ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាពក៏ប៉ុន្តែមិត្តសំឡាញ់ និងហ្វ្រេន្ឋអ៊ិនធីណាសិនណលមានគោលបំណងនឹងពង្រឹងបន្ថែមទៀតនៅឆ្នាំ ២០១១។<br><br>• អង្គការមិត្តសំឡាញ់ បានដាក់ពាក្យសុំឡើងវិញសំរាប់ប្រព័ន្ធវិញ្ញាបនត្រដែលមានលក្ខណះស្ម័គ្រចិត្តនៅក្នុងគម្រោងប្រតិបត្តិល្អរបស់អង្គការមិនមែនរដ្ឋាភិបាល (NGO-GPP) នាថ្ងៃទី ២ ខែ កក្កដា ឆ្នាំ២០១០ បន្ទាប់ពីវិញ្ញាបនត្របានផុតកំណត់ ហើយយើងនឹងដឹងលទ្ធផលនាពេលឆាប់ៗ នេះ។ |
| ៤.៣ គណៈគ្រប់គ្រងរបស់អង្គការមិត្តសំឡាញ់ (Mith | - រចនាសម្ព័ន្ធគ្រប់គ្រងទូទៅ ត្រូវបានអនុវត្ត នៅត្រីមាសទី៤នៃឆ្នាំ២០០៨។ | • គណៈគ្រប់គ្រងអង្គការមិត្តសំឡាញ់ និងអ្នកបច្ចេកទេសហ្វ្រេន្ឋអ៊ិនធីណាសិនណលបានផ្តល់ការគាំទ្រទៅដល់ប្រធានគំរោងទាំងអស់ និងអ្នកឯកទេសលើរចនាសម្ពន្ធ័ថ្មី ។ |

| | | |
|---|---|---|
| Samlanh) ផ្តល់នូវការគាំទ្រជាបន្តបន្ទាប់ដល់ក្រុមការងារ ។ | -ការផ្តល់យោបល់/ការវាយតម្លៃពីក្រុមអង្គការមិត្តសំឡាញ់ (Mith Samlanh) មាន លក្ខណៈវិជ្ជមាន ។ | • គណៈគ្រប់គ្រងបានធ្វើការកែលំអលើការគ្រប់គ្រង់ករណី និងប្រព័ន្ធអាជីវកម្មខ្នាតតូចដើម្បីបង្កើនការគាំទ្រដល់គ្រួសារ ។<br>• គណៈគ្រប់គ្រងអង្គការមិត្តសំឡាញ់ និងហ្វ្រេន្ឌអ៊ិនធើណាសិនណល បានរៀបចំដំណើរការឡើងវិញដោយប្រែឈ្មោះពី កាហ្វេ ដុយសង់ ទៅ ឡឺ កាហ្វេមិត្តសំឡាញ់ ពីខែកញ្ញា ឆ្នាំ២០១០ ។ |
| ៤.៤ ក្រុមប្រឹក្សាភិបាលរបស់អង្គការមិត្តសំឡាញ់(Mith Samlanh Board) ផ្តល់ការគាំទ្រ ជាវិជ្ជមានដល់អង្គការ និងការគ្រប់គ្រងរបស់អង្គការ ។ | - កិច្ចប្រជុំមានការចូលរួមយ៉ាងល្អ និងទៀងទាត់ ។<br>- ក្រុមប្រឹក្សាភិបាលផ្តល់ការគាំទ្រ ដូចមានចែងក្នុងលក្ខន្តិកៈ ។ | • នៅក្នុងឆ្នាំនេះ យើងបានប្រជុំក្រុមប្រឹក្សាភិបាលចំនួន ២ដង ដើម្បីពិភាក្សា និងរៀបចំកិច្ចសន្យាជាថ្មីជាមួយស្ថានទូតបារាំង រវាងភោជនីយដ្ឋានការហ្វេដុយសង់ បទបង្ហាញពីសមិទ្ធិផលការងាររបស់អង្គការមិត្តសំឡាញ់ប្រចាំឆមាសក្នុងឆ្នាំ២០១០ ដំណើរការគម្រោងប្រតិបត្តិល្អរបស់អង្គការមិនមែនរដ្ឋាភិបាល (NGO-GPP) សំរាប់ប្រព័ន្ធវិញ្ញាបនបត្រដែលមានលក្ខណៈស្ម័គ្រចិត្ត និងឯកភាពលើបទបញ្ជាផ្ទៃក្នុងរបស់អង្គការមិត្តសំឡាញ់ ។<br>• នាយិកាកម្មវិធីមិត្តសំឡាញ់ និងអ្នកគ្រប់គ្រង់បានទទួលការគាំទ្រពីសមាជិកក្រុមប្រឹក្សាភិបាលលើបទបញ្ជាផ្ទៃក្នុង ឡឺកាហ្វេមិត្តសំឡាញ់ និងហិរញ្ញវត្ថុ ។ |
| ***លទ្ធផលទី៥:នៅឆ្នាំ ២០១១ អង្គការមិត្តសំឡាញ់ (Mith Samlanh)ទទួលបានកម្មសិទ្ធិទាំងស្រុងលើអចលនទ្រព្យ (TC/EC)និងបានសាងសង់មជ្ឈមណ្ឌល ដែលផ្តល់នូវបរិយាកាសប្រកបដោយ គុណភាព សម្រាប់ការងាររបស់ខ្លួន ។*** | | |
| ៥.១ អង្គការមិត្តសំឡាញ់ (Mith Samlanh) បង្កើតរចនាសម្ព័ន្ធច្បាប់(កាន់កាប់ក្រុមហ៊ុន | - រចនាសម្ព័ន្ធច្បាប់បានបង្កើត ឡើងនៅត្រីមាសទី៤ នៃឆ្នាំ ២០០៨ ។ | • រចនាសម្ព័ន្ធច្បាប់បានបង្កើតរួចហើយតាំងពីឆ្នាំ២០០៩ ។ |

| | | |
|---|---|---|
| ៥.២ អង្គការមិត្តសំឡាញ់ (MithSamlanh) សងប្រាក់កម្ចីធនាគារ | - ការរៃអង្គាសមូលនិធិប្រព្រឹត្តទៅដោយប្រសិទ្ធភាព ។<br>- ការសងប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព នៅមុនកាលកំណត់របស់ធនាគារ ។ | • ប្រាក់ចំណូលចំនួន ១៣,២៨០.០៦ ដុល្លា បានមកពីការលក់ដុំតដ្ឋ និង Fun Fair ដើម្បីគាំទ្រដល់ការទិញដីនៃអង្គការមិត្តសំឡាញ់ ។<br>• អង្គការមិត្តសំឡាញ់បានសងប្រាក់ជូនធនាគារ ANZ Royal មុនពេលកំណត់ក៏ប៉ុន្តែ យើងមានកំម្ចីមួយទៀតជាមួយអង្គការ Give2Asia ដែលមានអត្រាការប្រាក់សមរម្យ ។ |
| ៥.៣ អង្គការមិត្តសំឡាញ់ (MithSamlanh) អនុម័តយល់ព្រមលើប្លង់អាគារនៅក្នុងបរិវេណ ដែលអនុគ្រោះចំពោះការពង្រីកពីមួយឆ្នាំទៅមួយឆ្នាំ ។ | - សម្រេចបានប្លង់ពង្រាងនៅ ត្រីមាសទី៣ នៃឆ្នាំ ២០០៨ ។<br>- សម្រេចចុងក្រោយលើប្លង់ ដោយមានយោបល់ពី ប្រភពផ្សេងៗនៅត្រីមាសទី៤ នៃឆ្នាំ ២០០៩ ។ | • សំរេចក្នុងឆ្នាំ២០០៩ ។<br>• សំរេចក្នុងឆ្នាំ២០០៩ ។ |
| ៥.៤ អង្គការមិត្តសំឡាញ់ (MithSamlanh) បានកសាងមជ្ឈមណ្ឌលរបស់ខ្លួន ។ | -មជ្ឈមណ្ឌលត្រូវបានសាងសង់រួចនៅត្រីមាស ទី៤ នៃឆ្នាំ ២០១១ ។ | • មិនទាន់បានចាប់ផ្តើមនៅឡើយ ។ |